# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




AsianInternationalJusticeInitiative(AIJI),aprojectofEast-WestCenterandUCBerkeleyWarCrimesStudiesCenter

*ជាឧបនាយកខ្យល់ រដ្ឋមន្ត្រីការពារប្រទេសខ្យល់ មេបញ្ជាការទ័ពខ្យល់ ខ្ញុំគ្មានឥទ្ធិពលអ្វីតែបន្តិចក៏គ្មានដែរ ។ តើខ្ញុំជាអ្នកមានអំណាចធំសម្បើមណាស់យ៉ាងនេះយ៉ាងនោះម៉េចនឹងកើត ?*

***-ជនជាប់ចោទលោក ខៀវ សំផន***

## *ជំពូកទី១ ៖* **ទិដ្ឋភាពទូទៅ**

បន្ទាប់ពីការឈប់សម្រាកកិច្ចដំណើរការនីតិវិធីនៅសប្តាហ៍មុន នាសប្តាហ៍នេះ សវនាការបានបន្តនីតិវិធីរបស់ខ្លួនដោយផ្តោតទៅលើប្រវត្តិសាស្ត្រនៃបក្សកុម្មុយនីស្តកម្ពុជា និងទំនាក់ទំនងនៃបទចោទប្រកាន់លើជនជាប់ចោទទាក់ទងទៅនឹងព្រឹត្តិការណ៍ដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

ជនជាប់ចោទទាំងបីរូប បានប្រកាន់ជំហររៀងៗខ្លួន ចំពោះការចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការ ដែលទំនងជាការលើកឡើងពេលនេះ បានឆ្លុះបញ្ចាំងពីការចូលរួមរបស់ពួកគាត់ក្នុងកិច្ចដំណើរការនីតិវិធីជាបន្តបន្ទាប់ទៀត ។ លោក **នួន ជា** បានបន្តឆ្លើយបំភ្លឺទៅនឹងសំណួរពីសំណាក់អង្គជំនុំជម្រះ និងតំណាងសហព្រះរាជអាជ្ញាជុំវិញបរិបទផ្សេងៗគ្នា ចាប់ផ្តើមពីមាគ៌ាយុទ្ធសាស្ត្រ និងយុទ្ធវិធីបក្សកុម្មុយនីស្តកម្ពុជារហូតដល់គម្រោងផែនការជម្លៀសប្រជាជនចេញពីភ្នំពេញ។ រីឯលោក **អៀង សារី** វិញ បានប្រើប្រាស់សិទ្ធិនៅស្ងៀម និងបដិសេធមិនធ្វើការអត្ថាធិប្បាយឡើយ នូវរាល់សំណួរទាំងឡាយណាដែលមិនពាក់ព័ន្ធនឹងជីវប្រវត្តិផ្ទាល់ខ្លួនរបស់គាត់។ ដោយឡែកលោក **ខៀវ សំផន** បានចូលរួមសហការណ៍ត្រឹមតែពាក់កណ្តាលដោយគាត់គ្រាន់តែបានអាននូវសេចក្តីថ្លែងការណ៍ដែលបានត្រៀមរួចជាស្រេច ដោយថ្លែងពីព្រឹត្តិការណ៍នានាដែលនាំឲ្យមានការកកើតឡើងនៃបក្សកុម្មុយនីស្តកម្ពុជា និងពីតួនាទីរបស់គាត់ក្នុងចលនាទាំងនោះ។ ទោះបីជាយ៉ាងនេះក្តី គាត់បានបដិសេធមិនឆ្លើយតបនឹងសំណួរណាមួយឡើយ និងបានស្នើសុំរក្សាសិទ្ធិនេះរហូតទាល់តែភាគីសហព្រះរាជាអាជ្ញាបានធ្វើបទបង្ហាញនូវភស្តុតាងនានាប្រឆាំងនឹងរូបគាត់ឲ្យចប់សព្វគ្រប់សិន។

នាសប្តាហ៍នេះផងដែរ តុលាការក៏បានស្តាប់សក្ខីកម្មបញ្ចប់របស់សាក្សី **ឡុង នរិទ្ធ** តាមរយៈការភ្ជាប់ប្រព័ន្ធសោតទស្សន៍ (វីដេអូលីង) ពីផ្ទះរបស់សាក្សី ទៅកាន់បន្ទប់សវនាការ ។ គួររម្លឹកផងដែរថា លោក **ឡុង នរិទ្ធ** គឺជាសាក្សីផ្ទៃក្នុងមួយរូបដែលធ្លាប់បានធ្វើការជាមួយលោក **អៀង សារី** នៅក្រសួងកិច្ចការបរទេសក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ជាទូទៅ សក្ខីកម្មរបស់លោក **ឡុង នរិទ្ធ** មិនសូវជាធ្វើទៅបានក្បោះក្បាយទេ ។ ជាញឹកញាប់ គាត់មិនសូវជាចងចាំរឿងរ៉ាវពីមុនមក ហើយចម្លើយវិញទៀតសោត ក៏មិនមានភាពស៊ីចង្វាក់គ្នានឹងសេចក្តីថ្លែងការណ៍ដែលធ្លាប់បានឆ្លើយជាមួយចៅក្រមស៊ើបអង្កេតដែរ ដែលប្រការទាំងនេះអាចបណ្តាលមកពីបញ្ហាសុខភាពរបស់គាត់ផង និងការរំខានផ្នែកបច្ចេកទេសផ្សេងៗក្នុងការផ្តល់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍ផងនោះ បានធ្វើឲ្យមានភាពរអាក់រអួលកើតឡើងជាយថាហេតុ ។

នៅចុងបញ្ចប់ ភាគីទាំងអស់បានលើកឡើងនូវបញ្ហានីតិវិធីមួយចំនួនដែលមានពាក់ព័ន្ធនឹងភាពអាចទទួលយកបាននៃឯកសារ និងយថាភាពនៃឯកសារភស្តុតាងដោយសារតែលោក **នួន ជា** បានទាមទារសុំឲ្យបង្ហាញឯកសារដើមឲ្យគាត់ឃើញ ក្នុងអំឡុងពេលនៃការតាំងសំណួរដេញដោលពីសំណាក់ភាគីសហព្រះរាជអាជ្ញា ។ បញ្ហាស្តីពីរបៀបរបបធ្វើការរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតដើម្បីទទួលបានសេចក្តីថ្លែងការណ៍ ឬចម្លើយនានាពីបុគ្គលដែលពួកគេបានធ្វើសម្ភាសន៍ ក៏ត្រូវបានរាប់បញ្ចូលក្នុងកិច្ចពិភាក្សានាសប្តាហ៍នេះផងដែរ។

## *ជំពូកទី២* ៖ **សក្ខីកម្មសង្ខេបចំពោះមុខអង្គជំនុំជម្រះ**

នៅសប្តាហ៍ទីពីរនៃសវនាការលើអង្គសេចក្តីនេះ ត្រូវបានចាប់ផ្តើមដោយការស្តាប់នូវសក្ខីកម្មរបស់ជនជាប់ចោទ **នួន ជា** និងសាក្សី **ឡុង នរិទ្ធ** ដែលជាសាក្សីដំបូងគេបង្អស់សម្រាប់ការជំនុំជម្រះនេះ។ បន្ថែមពីនេះ លោក **ខៀវ សំផន** បានប្រើប្រាស់ពេលវេលាជាងពីរម៉ោង រៀបរាប់អំពីជីវប្រវត្តិ និងទស្សនៈវិស័យរបស់គាត់ចំពោះសាវតានៃបក្សកុម្មុយនីស្តកម្ពុជា បូករួមទាំងការអះអាងទទួលស្គាល់ទៅលើទង្វើ និងសកម្មភាពណាខ្លះដែលគាត់បានជាប់ពាក់ព័ន្ធក្នុងរបបកម្ពុជាប្រជាធិបតេយ្យផងដែរ ។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏ជនជាប់ចោទរូបនេះ មិនព្រមផ្តល់ចម្លើយតបនឹងសំណួរណាមួយឡើយ ។ រីឯលោក **អៀង សារី** វិញ បានប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបដោយមិនកែប្រែឡើយនៅពេញមួយសប្តាហ៍នេះ ។

### ក. សក្ខីកម្មរបស់ជនជាប់ចោទ នួន ជា

នៅដើមសប្តាហ៍នេះ លោក **នួន ជា** បានជូនដំណឹងទៅកាន់អង្គជំនុំជម្រះថា ទោះបីជាគាត់បានឈប់សម្រាកកាលពីចុងសប្តាហ៍មុនក៏ពិតមែន ក៏ស្ថានភាពរបស់គាត់នៅពេលនេះនៅមិនទាន់ស្រួលបួលទេ និងថាគាត់នៅតែមានអារម្មណ៍ឆាប់អស់កម្លាំង និងវិលមុខ ។ ទោះជាយ៉ាងណា គាត់បានធានាថា គាត់នឹងព្យាយាមឲ្យអស់ពីលទ្ធភាពដើម្បីបំពេញភារកិច្ចជាមួយអង្គជំនុំជម្រះ និងបានស្នើសុំការអនុគ្រោះពីអង្គជំនុំជម្រះក្នុងករណីដែលគាត់ត្រូវការពេលវេលាសម្រាក ។ អង្គជំនុំជម្រះ បានកត់សម្គាល់ពីផលលំបាកនៅពេលគាត់ដើរជាមួយនឹងការប្រឹងទប់ជំហរមកកាន់រង្វង់ក្រចកសេះ (កន្លែងដែលជនជាប់ចោទអង្គុយដើម្បីផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការ)និងបានស្នើជនជាប់ចោទឲ្យអង្គុយលើកៅអីរុញ នៅពេលត្រូវចូលខ្លួនមកកាន់សវនាការនៅពេលក្រោយៗទៀត។ ការតាំងសំណួរដេញដោលទៅលើលោក **នួន ជា** ត្រូវបានធ្វើឡើងដោយចៅក្រម **ខាតរ៉ាយថ៍** (Judge Catwright) ចៅក្រម **ឡាវែន៍** (Judge Lavergne) និងសហព្រះរាជអាជ្ញាអន្តរជាតិ លោក

**ឌេល លីសាក់** (Mr. Dale Lysak) ។ ពួកគាត់បានចំណាយពេលលើសពីពាក់កណ្តាលនៃថិរវេលាដែលមានក្នុងសវនាការសប្តាហ៍នេះ។ ទោះបីជាវាមិនស៊ីពេលច្រើនក្តី លោក **នួន ជា** ច្រើនតែឆ្លើយតបមិនសូវចំនឹងសំណួរខ្លះៗដែលគេចោទសួរ និងច្រើនតែជាការរៀបរាប់ឡើងវិញនូវសេចក្តីថ្លែងការណ៍របស់គាត់ស្រដៀងគ្នានឹងអ្វីដែលគាត់បានលើកឡើងអំឡុងពេលនៃការធ្វើសេចក្តីថ្លែងការណ៍តបលើសវនាការបើកការចោទប្រកាន់ និងអំឡុងសវនាការកាលពីសប្តាហ៍មុន។ ជាថ្មីម្តងទៀតលោក **នួន ជា** បាននិយាយពីការលំបាកនៃការកសាងបដិវត្តន៍ និងបានធ្វើការពន្យល់បន្ថែមជុំវិញការឈ្លានពានរបស់ប្រទេសវៀតណាមមកលើកម្ពុជា ។ នៅចុងបញ្ចប់នៃសវនាការសប្តាហ៍នេះ លោក **នួន ជា** បានបដិសេធនឹងសំណួរពីភាគីសហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងអត្ថបទជាច្រើនដែលត្រូវបានដកស្រង់ចេញពី *ទស្សនាវដ្តីទង់បដិវត្តន៍* ដោយសារភាគីសហព្រះរាជអាជ្ញាមិនបានបង្ហាញឯកសារដើមដល់គាត់។

### *ក.១. ការហ្វឹកហ្វឺនក្នុងប្រទេសវៀតណាម និងមាតុភូមិនិវត្តន៍មកប្រទេសកម្ពុជាវិញ*

លោក **នួន ជា** បានបំភ្លឺឲ្យដឹងថា គាត់បានចូលរួមសិក្សាផ្នែកមនោគមន៍វិជ្ជានៅក្នុងព្រៃកាលពីឆ្នាំ ១៩៥៣ ។ គាត់បានបដិសេធថា គាតត់មិនបានចូលរួមក្នុងវគ្គហ្វឹកហ្វឺនយោធាឡើយ ប៉ុន្តែគាត់បានស្តាប់ ឮការជជែកពិភាក្សាផ្សេងៗពីបុគ្គលមួយចំនួនដែលធ្លាប់បានទទួលវគ្គហ្វឹកហាត់យោធាកន្លងមក ។ ជនជាប់ចោទក៏ធ្លាប់បានស្នាក់នៅក្នុងប្រទេសវៀតណាម រហូតទាល់តែកម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុងហ្សឺណែវក្នុងឆ្នាំ១៩៥៤។

នៅចន្លោះឆ្នាំ១៩៥៤ និងឆ្នាំ១៩៥៥ លោក **នួន ជា** ដែលត្រូវបានគេស្គាល់ថាជាបងធំទី២នៃរបបខ្មែរក្រហម បានវិលត្រឡប់មកប្រទេសកម្ពុជាវិញ។ ក្នុងអំឡុងពេលនោះហើយ ដែលគាត់បានជួបនឹងលោក **សាឡុត ស** ដែលគេក្រោយមកស្គាល់ថាជា **ប៉ុល ពត** ។ លោក **នួន ជា** បានបញ្ជាក់ថា រូបគាត់ និងលោក **សាឡុត ស** បានធ្វើជាជំនួយការឲ្យលោកតា **ទូ សាមុត** ដែលជាសមាជិកនៃគណៈមជ្ឈិមបក្សនៃប្រជាជនបដិវត្តន៍ខ្មែរ*(ដែលហៅកាត់ថាប.ជ.ប.ខ* ឬ***KPRP)***។[១] គាត់បានបដិសេធថា គាត់មិនដែលធ្លាប់បានកាន់តួនាទីជាលេខាបក្សនៃ *ប.ជ.ប.ខ* ឡើយ។ ទោះបីជាយ៉ាងនេះក្តី គាត់ក៏បានទទួលស្គាល់ថា គាត់ជាអ្នកទទួលបន្ទុកផ្នែកអប់រំគោលនយោបាយរបស់ *ប.ជ.ប.ខ* ដែលការងារនេះ ត្រូវបានចាប់ផ្តើមតាំងពីឆ្នាំ១៩៥៥មកម្ល៉េះ។

នៅចន្លោះឆ្នាំ១៩៥៩ ទៅ១៩៦១ មានការរៀបចំរចនាសម្ព័ន្ធបក្សឡើងវិញ ដោយសាតែលោក **ស៊ីវ ហេង** ដែលជាលេខាមជ្ឈិមបក្សនៃ *ប.ជ.ប.ខ* និងក៏ត្រូវជាអ៊ំសាច់ថ្លៃរបស់លោក **នួន ជា** កាលនោះបានចុះចូលទៅសារភាពជាមួយកងទ័ព **លន់ នល់**។ លោក **នួន ជា** ថ្លែងថាទំនងជាប៉ុន្មានឆ្នាំហ្នឹងហើយដែលគាត់បានជួបលោក **អៀង សារី** ។ នៅឆ្នាំបន្តបន្ទាប់មកទៀត លោក **នួន ជា** បានចុះទៅធ្វើការនៅតាមតំបន់ជនបទនានាដើម្បីស្តារក៏ដូចជាពង្រឹងសាខារបស់ *ប.ជ.ប.ខ*ផងដែរ ដោយបានចាប់ផ្តើមនៅតាមមូលដ្ឋានចំនួនពីរគឺ៖ មូលដ្ឋានរបស់ **តា ម៉ុក** នៅ*ស្រុកត្រាំកក់* និងមូលដ្ឋានរបស់ **ម៉ា ម៉ង់** នៅ*ឃុំពាម* ។

### *ក.២. មហាសន្និបាតបក្សលើកទី១ ក្នុងឆ្នាំ១៩៦០ និងមាគ៌ាយុទ្ធសាស្ត្ររបស់បក្សរហូតដល់ឆ្នាំ១៩៦៧*

យោងតាមលោក **នួន ជា** មាគ៌ានយោបាយរបស់បក្សដែលបានអនុម័តឡើងក្នុងអំឡុងពេលនៃមហាសន្និបាតបក្សលើកទី១ ក្នុងឆ្នាំ១៩៦០ ត្រូវបានដាក់ឲ្យប្រជុំពិភាក្សា និងបានដាក់ចេញការងារអភិវឌ្ឍជាលើក

ដំបូងដោយចាប់ពីថ្នាក់មូលដ្ឋាន រហូតដល់ថ្នាក់មជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា ដោយផ្អែកលើគោលការណ៍ *"ប្រជាធិបតេយ្យប្រមូលផ្តុំ"*។[២] លោក **នួន ជា** ក៏បានផ្តល់សក្ខីកម្មបញ្ជាក់ថា ការណ៍នេះធ្វើឡើងសំដៅលើ *"ការប្រមូលផ្តុំនៃគំនិតទស្សនៈវិស័យ និងចំណេះដឹងពីសមាជិកបក្សគ្រប់មជ្ឈមដ្ឋាន និងគណៈមជ្ឈិមបក្សផង ដែរ"*។[៣] ជាមួយគ្នានេះផងដែរ គោលការណ៍នៃ *"សមូហភាព"*[៤] មានន័យថា *"គ្រប់សមាជិកទាំងអស់ចូលរួមក្នុងអង្គប្រជុំពិភាក្សា ដើម្បីបញ្ចេញមតិយោបល់របស់ពួកគាត់"*[៥] ហើយរាល់បញ្ហាទាំងឡាយត្រូវមានការប្រជុំពិភាក្សារហូតទាល់តែមានការយល់ព្រមជាឯកច្ឆន្ទទើបអាចចេញសេចក្តីសម្រេចបាន។ លោក **នួន ជា** បានគូសបញ្ជាក់ត្រង់ចំណុចនេះផងដែរថា គោលការណ៍ *"សមូហភាព"* ត្រូវបានយកមកអនុវត្តចាប់ពីមហាសន្និបាតឆ្នាំ១៩៦០ ហើយជាបន្តបន្ទាប់នៅក្នុងអំឡុងពេលមានកិច្ចប្រជុំគណៈកម្មាធិការម្តងៗ រួមបញ្ចូលទាំងគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍។

នៅចន្លោះឆ្នាំ១៩៦០ ដល់១៩៦៧ គឺជាដំណាក់កាលនៃការធ្វើ *"បដិវត្តន៍ប្រជាធិបតេយ្យ"* ដែលជនជាប់ចោទរូបនេះ បានកំណត់ថាជា*"ការកម្ចាត់កម្ទេលពួកអាណានិគមដែលជិះជាន់ប្រជាជន។ ក្រុមពួកកាកសំណល់ទាំងនោះ នៅមានហើយបានទទួលអំណាចពីពួកសក្តិភូមិ"*។[៦] ដូច្នេះហើយ គោលបំណងសំខាន់នៃការធ្វើបដិវត្តន៍សម័យនោះ គឺត្រូវកែប្រែជីវភាពរស់នៅរបស់ប្រជាជន។

ចំណុចគួរឲ្យកត់សម្គាល់នោះនៅត្រង់ថាលោក **នួន ជា** បានរៀបរាប់ពីការតស៊ូនយោបាយ និងការបង្កើត*កងការពារសម្ងាត់* ក្នុងអំឡុងពេលចន្លោះឆ្នាំ១៩៦០ និង ឆ្នាំ១៩៧៦ ។ គោលបំណងនៃការបង្កើតកងការពារសម្ងាត់នេះ គឺដើម្បីជូនដំណើរ និងការពារកម្មាភិបាល។ កងការពារសម្ងាត់នេះ ត្រូវបានជ្រើស ចេញពីកូនចៅកសិករ ។ ពួកគេប្រដាប់ដោយដំបង កាំបិត និងពូថៅដៃតែប៉ុណ្ណោះ។ នៅពេលមានការលើកឡើងនូវអត្ថបទដកស្រង់ចេញពីទស្សនាវដ្តី*ទង់បដិវត្តន៍* ពីភាគីម្ចាស់សំណួរដែលថាកងការពារសម្ងាត់មានសមត្ថកិច្ច *"វាយកម្ទេចជាសម្ងាត់"*[៧] ទៅលើសត្រូវ លោក **នួន ជា** បានអះអាងថា កងការពារសម្ងាត់មិនមានតួនាទីសម្រាប់វ៉ៃ ឬ*"កម្ទេច"*សត្រូវនោះឡើយ។ ត្រង់ចំណុចនេះ លោក **នួន ជា** បានបញ្ជាក់ថា ជាទូទៅ សមាជិកនៃកងការពារសម្ងាត់ មិនមានភារកិច្ចស្វែងរកពួកគិញដើម្បីកម្ទេចនោះទេ តែមានសមត្ថកិច្ចកម្ចាត់ពួកគិញណាដែលបានបន្លំចូលរួមការប្រជុំបក្ស ដើម្បីអាចកំណត់សមាសភាពបុគ្គលសំខាន់របស់បក្សបាន ក្នុងបំណងចាប់ខ្លួនអ្នកចូលរួមប្រជុំផ្សេងទៀតនៅពេលមានឱកាស។

## *ក.៣. ការតស៊ូអាវុធ និងការចាប់កំណើតនៃកងទ័ពបដិវត្តន៍កម្ពុជាក្នុងឆ្នាំ១៩៦៨*

យោងទៅតាមជនជាប់ចោទ ការប្រព្រឹត្តអំពើជិះជាន់សង្កត់សង្កិន និងទង្វើឃោរឃៅរបស់ពួក **លន់ នល់** ទៅលើកសិករក្រីក្រនៅស្រុក*សំឡូត* បាននាំឲ្យមានចលនាប្រឆាំងវាយកម្ទេចប៉ុស្តិ៍ប៉ូលិសនៅភូមិ*បាយដំរាំ* ភាគខាងជើងខេត្ត*បាត់ដំបង* កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៦៨។ ត្រង់ចំណុចនេះ លោក **នួន ជា** បានបរិយាយដោយរៀបរាប់ថា មានយុវជនប្រាំពីរនាក់មកពី *"កងជីវពល"* ឬកងស្ម័គ្រចិត្ត ដែលជាកូនចៅប្រជាជនកសិករក្រីក្រដែលត្រូវគេធ្វើបាប ឬកាប់សម្លាប់ និង *"មិនអាចទ្រាំនឹងស្ថានភាពបែបនេះបានតទៀត"*[៨] ពួកគេបានវាយកម្ទេចប៉ុស្តិ៍ប៉ូលិស និងដណ្តើមយកអាវុធមកកាន់កាប់។ នេះសបញ្ជាក់ឲ្យឃើញច្បាស់ថា ការតស៊ូអាវុធបានចាប់រីកសុសសាយពីតំបន់មួយទៅកាន់តំបន់មួយទៀត ពីភូមិភាគពាយព្យទៅកាន់ភូមិភាគនិរតីជាដើម។ លោក **នួន ជា** បានរៀបរាប់ម្តងទៀតថា បន្ទាប់ពីមានបណ្តាជនធ្វើបដិវត្តន៍នៅភូមិភាគពាយព្យបាន

កាន់កាប់អាវុធយ៉ាងច្រើនសន្ធឹកមក ការតស៊ូអាវុធបានចាប់រីកដុះដាលទៅដល់ភូមិភាគបស្ចិម។ លោក **នួន ជា** បានប្រកាសដោយម៉ឺងម៉ាត់ថា *"ចលនាបដិវត្តន៍នេះមិនមែនមកពីប្រជាជនកសិករកាចសាហាវ និងឃោរឃៅនោះទេ គឺមកពីការប្រព្រឹត្តយ៉ាងអាក្រក់របស់* ***លន់ នល់*** *(បក្សពួក) និង* ***សិរិមតៈ សឹង ង៉ុកថាញ់*** *និង* ***គូ រុន...****"*។[៩] ទោះបីជាលោក **នួន ជា** បានបង្ហាញពីការគាំទ្រចំពោះការងើបបះបោររបស់ប្រជាជនកសិករទាំងនោះក៏ដោយ ក៏គាត់បានធ្វើការបដិសេធចំពោះការចោទប្រកាន់ថារូបគាត់ ជាអ្នកចេញបញ្ជាឲ្យវាយកម្ទេចប៉ុស្តិ៍ប៉ូលិស ដូចដែលមានការលើកឡើងក្នុងដីកាដំណោះស្រាយ។ គាត់ក៏បានអះអាងបន្ថែមថា កាលណោះ គាត់មិនមានវត្តមាននៅស្រុក*សំឡូត* នោះទេ ។

ចៅក្រម **ខាតរ៉ាយច៍** បានអានកំណត់ហេតុដែលជាអត្ថបទក្នុងទស្សនាវដ្ដី*ទង់បដិវត្តន៍* ថា ការបះបោរនៅកាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៦៨ ត្រូវបានកំណត់ថាជាការចាប់កំណើតនៃកងទ័ពបដិវត្តន៍កម្ពុជា។ ចំណុចនេះ ធ្វើឲ្យលោក **នួន ជា** និយាយតបថា ការពិត កងទ័ពបដិវត្តន៍កម្ពុជាត្រូវបានបង្កើតឡើងនៅថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៦៨ ។ គាត់បាននិយាយបន្តទៀតថា សមាជិកបក្សទាំងអស់ និងប្រទេសចិន បានផ្ដល់មូលនិធិគាំទ្រដល់កងទ័ពបដិវត្តន៍កម្ពុជា។ រីឯប្រទេសវៀតណាមវិញ បានជំទាស់នឹងការតស៊ូអាវុធរបស់បក្សកុម្មុយនីស្តកម្ពុជា និងបានបង្ខាំងអាវុធដែលចិនផ្តល់មកឲ្យកម្ពុជា ខណៈដែលត្រូវដឹកឆ្លងកាត់ប្រទេសនេះ ។ ជាងនេះទៅទៀត លោក **នួន ជា** បានពន្យល់ថា ការតស៊ូនយោបាយ គឺជាមូលដ្ឋានសំខាន់នៃការតស៊ូអាវុធ ដែលជាមាគ៌ាតែមួយគត់ក្នុងការឈានទៅដល់បដិវត្តន៍ប្រជាធិបតេយ្យ និងប្រជាជាតិ។ គាត់បានថ្លែងថា តពីព្រឹត្តិការណ៍នានាទាំងនេះ ការអនុវត្តន៍ទ្រឹស្តីសង្គមនិយម និងកុម្មុយនីស្តត្រូវបានអនុវត្តជាបន្តបន្ទាប់មក ។

### *ក.៤. សម្ព័ន្ធភាពបក្សកុម្មុយនីស្តកម្ពុជា និង* ***ព្រះករុណាសម្ដេច នរោត្តម សីហនុ*** *បន្ទាប់ពីរដ្ឋប្រហាររបស់ លន់ នល់ នៅឆ្នាំ១៩៧០*

នៅថ្ងៃទីពីរនៃសវនាការសប្តាហ៍នេះ លោកចៅក្រម **ឡាវែន៍** (Lavergne) បានតាំងសំណួរដេញដោលអំពីតួនាទីរបស់ព្រះមហាក្សត្រ **នរោត្តម សីហនុ** ក្នុងបក្សកុម្មុយនីស្តកម្ពុជា ។ លោក **នួន ជា** បានទទួលស្គាល់ថាបក្សកុម្មុយនីស្តកម្ពុជា *"មិនមែនគ្រាន់តែធ្វើឲ្យមានសម្ព័ន្ធភាពល្អជាមួយព្រះអង្គប៉ុណ្ណឹងទេ ថែមទាំងទុកព្រះអង្គជាបុគ្គលដែលជាទីគោរពបូជារបស់បប្រជាជនកម្ពុជា"*។[១០] មូលដ្ឋាននៃសម្ព័ន្ធភាពនេះ គឺជាសមរភូមិមុខរបស់កម្ពុជាប្រជាប្រធិបតេយ្យ ដែលបានជំរុញឲ្យកាន់តែមានសន្ទុះក្លាំងក្លានៃការប្រមូលកម្លាំងជាអតិបរមា ។ ជនជាប់ចោទរូបនេះ បានពន្យល់បន្ថែមថា សមរភូមិមុខ ត្រូវការប្រមូលកម្លាំងពីគ្រប់ជាន់ថ្នាក់ និងគ្រប់ទីកន្លែងទាំងអស់ឲ្យតែជាអ្នកស្នេហាជាតិ និងជាអ្នកជាតិនិយម បូករួមទាំងព្រះរាជវង្សានុវង្ស និងព្រះមហាក្សត្រ ។ ទោះជាយ៉ាងណា កម្ពុជាប្រជាប្រធិបតេយ្យ មិនបានរាប់បញ្ចូលនូវសមាសភាពដែលជាបរិវាររបស់*"ចក្រពត្តិនិយម"* ឡើយ ។

យោងតាមសក្ខីកម្មរបស់លោក **នួន ជា** បក្សកុម្មុយនីស្តកម្ពុជា ត្រូវការពង្រឹងចំណងសម្ព័ន្ធភាពជាមួយ **សម្ដេច សីហនុ** បន្ទាប់ពីព្រះអង្គត្រូវបានធ្វើរដ្ឋប្រហារផ្ដួលរំលំដោយ **លន់ នល់** នៅឆ្នាំ១៩៧០ ។ នៅពេលដែលព្រះករុណាបានយាងចេញពី*ប៉េងកាំង* មកប្រទេសកម្ពុជានៅឆ្នាំ១៩៧៣ បក្សកុម្មុយនីស្តកម្ពុជាបានរៀបចំពិធីទទួលព្រះអង្គដោយមហាកិត្តិយស ដែលមានការទទួលស្វាគមន៍យ៉ាងកក់ក្តៅដោយលោក **ប៉ុល ពត** លោក **សុន សេន** និងលោក **អៀង សារី** ។ លោក **នួន ជា** បានផ្តល់សក្ខីកម្មថា គាត់មិនបានចូលរួមក្នុងពិធីជប់លៀងទទួលស្វាគមន៍ការយាងមកដល់របស់ព្រះមហាក្សត្រទេ ពីព្រោះនៅពេលនោះគាត់ស្ថិតនៅ

ក្នុង*ស្រុកកំពង់ក្រោម* ។ ក្រោយពីបានទទួលការណែនាំពីលោក **ប៉ុល ពត** ជនជាប់ចោទរូបនេះ មាននាទីដឹកនាំការងារផ្នែករក្សាសន្តិសុខដល់ការយាងមកដល់របស់ **សម្តេច សីហនុ** ចំនួនប្រាំពីរថ្ងៃទៅកាន់ក្រុងអង្គរ ក្នុង*ខេត្តសៀមរាប*។ លោក **នួន ជា** បានរម្លឹកឡើងវិញថា ប្រជាជនដែលរស់នៅខេត្តជិតខាងនានា មានទាំងព្រះសង្ឃជាច្រើនផងដែរ បាននាំគ្នាប្រារព្ធពិធីសាសនាផ្សេងៗ ដើម្បីស្វាគមន៍ព្រះរាជទស្សនកិច្ចរបស់ព្រះមហាក្សត្រ ។ ជនជាប់ចោទរូបនេះ បានរៀបរាប់បន្ថែមថា ព្រះអង្គទ្រង់សព្វព្រះទ័យជាខ្លាំងចំពោះព្រះរាជទស្សនកិច្ចលើកនេះរបស់ព្រះអង្គ ថែមទាំងបានសម្តែងនូវការកោតសរសើរ និងដឹងគុណជាខ្លាំងដល់ថ្នាក់ដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលបានរក្សាសុវត្ថិភាពថ្វាយព្រះអង្គ ។ លោក **នួន ជា** បានបញ្ជាក់ថា តាមរយៈលេខាបក្ស គឺលោក **ប៉ុល ពត** បក្សកុម្មុយនីស្តកម្ពុជា *"បានរៀបចំអ្វីគ្រប់បែបយ៉ាងដើម្បីការពារសន្តិសុខថ្វាយដល់ព្រះអង្គ"*។[១១]

### *ក.៥. សក្ខីកម្មរបស់លោក នួន ជា ពាក់ព័ន្ធនឹងលទ្ធិកុម្មុយនីស្ត និងព្រះពុទ្ធសាសនា*

យោងតាមលោក **នួន ជា** លទ្ធិកុម្មុយនីស្ត និងព្រះពុទ្ធសាសនា អាចនៅជាមួយគ្នាបាន ។ នៅក្នុងសក្ខីកម្មរបស់គាត់នាសប្តាហ៍នេះ ជនជាប់ចោទបានកត់សម្គាល់ថា ទោះបីជាពេលខ្លះលទ្ធិទាំងពីរខុសគ្នាក៏ពិតមែន ក៏នៅមានទ្រឹស្តីមួយចំនួនមានភាពដូចគ្នាផងដែរ ។ អង្គជំនុំជម្រះសាលាដំបូង បានអនុញ្ញាតឲ្យលោក **នួន ជា** បរិយាយពីខ្លឹមសារនេះ ដូច្នេះហើយជនជាប់ចោទក៏បានលើកយកឧទារហ៍ជាច្រើនដើម្បីធ្វើការពន្យល់ពីគំនិតបដិវត្តន៍របស់បក្សកុម្មុយនីស្តកម្ពុជា ធៀបនឹងព្រះពុទ្ធសាសនា ចំពោះទំនាក់ទំនងដែលមានឲ្យគ្នាទៅវិញទៅមកយ៉ាងដូច្នេះថា៖

> *តាមទស្សនៈរបស់ខ្ញុំ នៅក្នុងទ្រឹស្តីបដិវត្តន៍ សញ្ញាណនៃទ្រឹស្តីសម្ភារៈនិយមបដិច្ចសមុប្បាទដូចនឹងព្រះពុទ្ធសាសនាដែរ ។ ប្រើធម៌បដិច្ចសមុប្បាទ គឺមានកើតមានរលត់ ។ ក្នុងបដិវត្តន៍ក៏ប្រហាក់ប្រហែលនឹងព្រះពុទ្ធសាសនាដែរ ដែលប្រដៅឲ្យមនុស្សចេះមេត្តា ករុណា ឧបេក្ខា អាណិតអាសូរ និងជួយសង្គ្រោះគ្នាទៅវិញទៅមក ។ ប្រហាក់ប្រហែលនៅត្រង់ថា ទ្រឹស្តីបដិវត្តន៍ គឺកុំប្រើអំណាច កុំអាជ្ញា កុំស្រី កុំស្រា កុំលុយ កុំកាក់ កុំលេងល្បែងស៊ីសង ហើយខាងសាសនាក៏មានការអប់រំដូច្នេះដែរ ។ ប៉ុន្តែខាងបដិវត្តន៍ បើចាំបាច់គេឈ្លានពាន គេប្រើអាវុធ យើងក៏ត្រូវប្រើហិង្សាអាវុធដែរ។ ដូច្នេះ ខ្លះដូចគ្នា ខ្លះក៏មិនដូច ត្រង់ថាទ្រឹស្តីសាសនា គឺយកការខន្តីជាបឋម។*[១២]

លោក **នួន ជា** បានទទួលស្គាល់ថា បក្សកុម្មុយនីស្តកម្ពុជាបានកម្ទាត់មនុស្សណាដែលមិនអាចប្រៀនប្រដៅបាន និងអ្នកទាំងឡាយណាដែលមានចេតនាបំផ្លិចបំផ្លាញជាតិ ។ ប៉ុន្តែក្រោយពីនេះ គាត់បានពោលអះអាងថា *"បក្សគ្មានសិទ្ធិទៅកម្ទេចនរណាទេ"* [១៣] ហើយនិងបានលើកយកឧទាហរណ៍មកបញ្ជាក់ដូចខាងក្រោមនេះ៖

> *ខ្ញុំដូចជាជម្រាបហើយជម្រាបទៀត បក្សកុម្មុយនីស្តកម្ពុជាវាមិនមែនស្អាតស្អំមួយរយភាគរយទេ ពីព្រោះវាមិនមែនចុះពីលើឋានសួគ៌ឯណា វាកើតនៅក្នុងសង្គមពុករលួយដែរ។ ដូច្នោះការកសាងបក្សនៅក្នុងដែលស្មុគស្មាញនេះ វាដូចតែគ្នាទេ ។ អ្នកខ្លះក៏កសាងបាន អ្នកខ្លះក៏កសាង*

*មិនបាន ។ អ្នកណាដែលគេកសាងបានក៏គេទៅល្អទៅ អ្នកណាកសាងមិនបានក៏បណ្តេញចេញឲ្យចេញពីបក្សទៅ និងក៏បញ្ជូនឲ្យទៅធ្វើការកន្លែងផ្សេងទៅធ្វើពលកម្ម ធ្វើអីទៅ ។*[១៤]

ព្រះរាជអាជ្ញា **លីសាក់** បានចោទសួរពីហេតុផលដែលលោក **នួន ជា** មិនដែលថ្លែងនូវការគោរពដល់ព្រះសង្ឃនៅក្នុងសុន្ទរកថារបស់គាត់អំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ក៏ប៉ុន្តែទើបតែបានថ្លែងនូវការគោរពក្នុងពេលត្រូវផ្តល់សក្ខីកម្មក្នុងបន្ទប់តុលាការទៅវិញ ។ គួរបញ្ជាក់ថា លោក **នួន ជា** បានសម្តែងនូវការគោរពចំពោះព្រះសង្ឃដែលមានវត្តមាននៅក្នុងសាលសាធារណៈ មុនពេលគាត់ចាប់ផ្តើមផ្តល់សក្ខីកម្ម ដោយនិយាយថា "សូមក្រាបថ្វាយបង្គំព្រះតេជគុណ..."។ លោក **នួន ជា** បានឆ្លើយតបថា គាត់មិនចង់ឲ្យមានការលាយឡំរវាងសាសនាជាមួយនឹងនយោបាយនោះទេ ហើយកាលពីសម័យនោះទៀតសោតក៏ពុំមានវត្តមានរបស់ព្រះសង្ឃចូលរួមស្តាប់នៅពេលគាត់កំពុងថ្លែងសុន្ទរកថាឡើយ។ គាត់បានបន្ថែមទៀតថា បុគ្គលណាដែលនិយាយថាកម្ពុជាប្រជាធិបតេយ្យបំផ្លាញព្រះពុទ្ធសាសនា បុគ្គលនោះមិនយល់ពីព្រះពុទ្ធសាសនានោះទេ។ គាត់ថ្លែងថា៖ *"បក្សមិនដែលដាក់កម្រិតហាមឃាត់ណាមួយទៅលើព្រះពុទ្ធសាសនានោះឡើយ"*។[១៥]

### *ក.៦. ការជម្លៀសចេញពីភ្នំពេញ*

យោងតាមជនជាប់ចោទ **នួន ជា** សេចក្តីសម្រេចទៅលើការជម្លៀសប្រជាជនចេញពីភ្នំពេញ និងពីបណ្តាទីប្រជុំជននៃទីរួមខេត្តនានា ត្រូវបានធ្វើឡើងនៅក្នុងកិច្ចប្រជុំគណៈមជ្ឈិមជាបន្តបន្ទាប់ដែលបានចាប់ផ្តើមឡើងតាំងពីឆ្នាំ១៩៧៣ មកម្ល៉េះ ដោយរួមមានទាំងកិច្ចប្រជុំវិសាមញ្ញនៃគណៈអចិន្ត្រៃយ៍នៅពាក់កណ្តាលឆ្នាំ១៩៧៤ផងដែរ ។ លោក **នួន ជា** បានផ្តល់សក្ខីកម្មទាក់ទងនឹងមូលហេតុដែលនៅពីក្រោយការជម្លៀសនេះថា មកពីកង្វះខាតស្បៀងអាហារ និងភាពអត់ឃ្លានបានកើតឡើងនៅភ្នំពេញតាំងពីឆ្នាំ១៩៧២ ហើយដែលរដ្ឋាភិបាលលោក **លន់ នល់** មិនអាចគ្រប់គ្រងបានឡើយ ។ គាត់បានពន្យល់ថា ទោះបីជានៅទីជនបទពុំមានស្បៀងអាហារ និងសម្ភារៈសម្បូរហូរហៀរយ៉ាងណាក៏ដោយ ក៏នៅទីនោះប្រជាជនបានរស់នៅក្នុងសហករណ៍ និងអាចជួយសង្គ្រោះគ្នាទៅវិញទៅមកបាន។ ចំពោះមូលហេតុមួយទៀតនោះ គឺថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានធ្វើការចោទប្រកាន់វៀតណាមថា មានបំណងចង់ប្រើប្រាស់អំណាចគ្រប់គ្រងលើកម្ពុជាតាមរយៈការរំដោះយកភ្នំពេញ និងបានប្រាប់ខ្មែរក្រហមឲ្យរងចាំក្រោយពេលគេវ៉ៃយកបានព្រៃនគរសិន គេនឹងជួយវាយយកភ្នំពេញ ដោយគ្រាន់តែឲ្យខ្មែរក្រហមជាអ្នកនាំផ្លូវតែប៉ុណ្ណោះ(គាត់ពន្យល់ថា ដើម្បីមានឯករាជ្យម្ចាស់ការលើប្រទេសខ្លួនឯង កងទ័ពខ្មែរក្រហមត្រូវតែវាយយកភ្នំពេញឲ្យបានមុនការលូកដៃនៃវៀតណាម ។ គាត់ថា បើវៀតណាមវាយបាន នោះភាពឯករាជ្យម្ចាស់លើប្រទេសខ្លួនឯងនឹងលែងមាន ពោលគឺ វៀតណាមនឹងក្លាយជាអ្នកគ្រប់គ្រងដោយស្វ័យប្រវត្តិ) ។ តាមការសន្និដ្ឋានរបស់លោក **នួន ជា** ប្រសិនបើ*វៀតណាម*វាយរំដោះយកភ្នំពេញបានជោគជ័យនោះ វានឹងមានការពិបាកក្នុងការទប់ទល់នឹងពួកកងទ័ព **លន់ នល់** ផងកងទ័ពវៀតណាមផងពួកឈ្មោភស្រីញី ចោរប្លន់ និងពួកអ្នកលេងអាវ៉ាសែជាដើម ដែលជាប្រការនាំឲ្យមានភាពអសន្តិសុខ និងអាចនាំឲ្យមានការស្លាប់ដល់ប្រជាជនស្លូតត្រង់កាន់តែច្រើន ទើបបក្សសម្រេចជម្លៀសបណ្តោះអាសន្នសិន រងចាំមើលសភាពការណ៍ជាបន្តទៀត។ ដូច្នេះហើយ ការជម្លៀសប្រជាជនចេញពីភ្នំពេញ គឺជាមធ្យោបាយបញ្ចៀសការគំរាមកំហែងហានិភ័យខាងលើនេះមិនឲ្យកើតមានឡើង ។ មូលហេតុចុងក្រោយដែលថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានសម្រេចចិត្តធ្វើការជម្លៀសប្រជាជនចេញពីភ្នំពេញ និងតាមបណ្តា

ទីប្រជុំជនមួយចំនួនទៀតគឺដើម្បីប្រឆាំងនឹងការកំណត់យុទ្ធសាស្ត្រនយោបាយរបស់សហរដ្ឋអាមេរិក និងវៀតណាម។

យោងទៅតាមជនជាប់ចោទ **នួន ជា** បក្សកុម្មុយនីស្តកម្ពុជា បានបំបែកប្រជាជនឲ្យទៅរស់នៅតាមបណ្តាខេត្តនានា ដោយធ្វើការបែងចែកពួកគេទៅតាមអាយុ តាមវ័យដែលអាចធ្វើស្រែចម្ការបាននៅតាមតំបន់ផ្សេងៗ ។ គាត់បានអះអាងបញ្ជាក់ថា អ្នកណាដែលជម្លៀសចេញមកពីទីក្រុងត្រូវបានចាត់ចែងឲ្យធ្វើការងារជួយប្រជាជនមូលដ្ឋាន ក៏ប៉ុន្តែអ្នកទាំងនោះមិនដែលធ្លាប់ធ្វើស្រែពីមុនមកទេ ដូច្នេះ ពួកគេគ្រាន់តែធ្វើការងារណាងាយៗ ឬស្រាលៗតែប៉ុណ្ណោះ។ ចំពោះរបបអាហារវិញ លោក **នួន ជា** បាននិយាយថា៖ ពួកគេទទួលបានអាហារបីពេលក្នុងមួយថ្ងៃ និងមានបង្អែមម្តងក្នុងមួយសប្តាហ៍ផងដែរ ។ ទោះជាយ៉ាងណាក្តី នៅមាន“*សមាសភាពមិនល្អ*” ដែលចង់បំផ្លាញសហករណ៍បាននាំឲ្យមានការបែងចែករបបអាហារមិន ដូចគ្នា ។ លោក **នួន ជា** បានបរិយាយត្រង់ចំណុចនេះថា នៅពេលគាត់ និងកម្មាភិបាលនៃបក្សកុម្មុយនីស្តកម្ពុជាបានចុះត្រួតពិនិត្យសហករណ៍គាត់មើលឃើញពួកសមាសភាពមិនល្អនេះ ជា “*អ្នកដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភ និងសាច់ឈាមល្អដោយមិនមានរាងស្គមស្គាំងឡើយ*”[១៦]។ លោក **នួន ជា** បាននិយាយបន្តថា “*នៅពេលដែលពួកគេបានដឹងថាគណៈមជ្ឈិមចុះមកសួរសុខទុក្ខនៅតាមមូលដ្ឋាន ពួកគេបានទទួលគណៈមជ្ឈិមដោយបានរៀបចំឲ្យមានការកំសាន្ត និងមានផ្តល់អាហារបានយ៉ាងល្អគ្រប់គ្រាន់ ។ ពួកគេបានទទួលគណៈមជ្ឈិមដោយមានសាច់មាន់ និងសាច់គោទៀតផង*”។[១៧]

លោក **នួន ជា** បានឲ្យដឹងថា ប្រជាជនដែលរស់នៅតាមបណ្តាទីក្រុងតូចៗក៏ដូចគ្នានឹងភ្នំពេញដែរត្រូវបានធ្វើការជម្លៀសចេញទាំងអស់ បន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ គណៈភូមិភាគបានសម្រេច និងអនុវត្តការជម្លៀសនេះដោយមានការអនុម័តពីគណៈមជ្ឈិមផងដែរ។

### *ក.៧. តួនាទីរបស់លោក អៀង សារី និងលោក ខៀវ សំផន ក្នុងការជម្លៀសប្រជាជន*

នៅពេលដែលចៅក្រម **ឡាវែន៍** បានសួរនាំអំពី“*ចលនាកុម្មុយនីស្តលួចលាក់របស់កម្ពុជា ថាតើធ្លាប់មានទំនាក់ទំនងអ្វីជាមួយនឹងបញ្ញវន្តចម្រើននិយម ដែលក្នុងមានលោក* ***ខៀវ សំផន****ដែរឬអត់*”។[១៨] លោក **នួន ជា** បាននិយាយថា លោក **ប៉ុល ពត** និងលោក **អៀង សារី** ប្រហែលធ្លាប់មានទំនាក់ទំនងជាមួយក្រុមនេះ ហើយគាត់ក៏បានបន្តផ្តល់សក្ខីកម្មថា លោក **ប៉ុល ពត** បានប្រាប់គាត់មិនឲ្យរវល់នឹងក្រុមបញ្ញវន្តចម្រើននិយមនេះឡើយ ពីព្រោះគាត់ “*មិនចេះនិយាយភាសាបញ្ញាជន*”។[១៩] លុះក្រោយមក បន្ទាប់ពីកិច្ចព្រមព្រៀងទីក្រុង*ហ្សឺណែវ* លោក **នួន ជា** បានជួបនឹងលោក **អៀង សារី** ក៏ប៉ុន្តែគាត់មិនបានជួបជាមួយនឹងលោក **ខៀវ សំផន** ទេ រហូតទាល់តែធ្វើការរំដោះភ្នំពេញបានហើយ ។

លោក **នួន ជា** បានធ្វើការកត់សម្គាល់បន្ថែមថា នៅពេលមានកិច្ចប្រជុំនៅពាក់កណ្តាលឆ្នាំ១៩៧៤ លោក **អៀង សារី** និងលោក **ខៀវ សំផន** ពុំមានវត្តមានក្នុងកិច្ចប្រជុំនោះទេ ។ កិច្ចប្រជុំមួយនេះ ដែលរៀបចំឡើងដោយគណៈអចិន្ត្រៃយ៍ គឺធ្វើឡើងដើម្បីសម្រេចឲ្យមានការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ។ ពេលនោះ លោក **អៀង សារី** ជាអ្នករាយការណ៍នៅឯបរទេស រីឯលោក **ខៀវ សំផន** មិនមែនជាសមាជិកនៃគណៈអចិន្ត្រៃយ៍នៅឡើយទេ ពោលគឺគាត់មានភារកិច្ចផ្សេងទៀត ។ ជុំវិញបញ្ហានេះផងដែរ លោក **នួន ជា** មិនអាចនិយាយថាតើពេលវេលាណាដែលសហជនជាប់ចោទទាំងពីររូបនេះ បានដឹងឮពីសេចក្តីសម្រេចស្តីពីការជម្លៀសនេះឡើយ ។ លោក **នួន ជា** បានថ្លែងថា លោក **ខៀវ សំផន** មិនមានឋានៈជាសមាជិកភូមិភាគនៅ

ក្នុងកិច្ចប្រជុំកាលណោះទេហើយគាត់ក៏មិនអាចចងចាំថាតើលោក **ខៀ សំផន** មានឋានៈជាសមាជិកគណៈមជ្ឈិមដែរ ឬអត់ឡើយ ។ នៅពេលដែលមានសំណួរទាក់ទងនឹងពេលវេលាណា ដែលលោក **ខៀវ សំផន** បានក្លាយជាសមាជិកពេញសិទ្ធិនៃគណៈអចិន្ត្រៃយ៍ លោក **នួន ជា** បាននិយាយថា គាត់មិនអាចចាំកាលបរិច្ឆេទពេលនោះឡើយ ។ ទាក់ទងនឹងលោក **អៀង សារី** វិញ លោក **នួន ជា** បានអះអាងថាគាត់មិនបានដឹងថាលោក **អៀង សារី** ហ្នឹងមានតួនាទីជាអ្វីឲ្យពិតប្រាកដនោះទេ ។ លោក **នួន ជា** បានផ្តល់សក្ខីកម្មថាគាត់គ្រាន់តែដឹងថា លោក **អៀង សារី** ធ្លាប់មានទំនាក់ទំនងជាមួយបក្សកុម្មុយនីស្តកម្ពុជាតាំងពីនៅ*ប៉េងកាំង* មកម្ល៉េះ ។ លោក **នួន ជា** បានថ្លែងថា ដោយសារវប្បធម៌នៃការរក្សាការសម្ងាត់របស់បក្សកុម្មុយនីស្តកម្ពុជា ទើបគាត់មិនបានដឹងពីតួនាទី ឬទំនួលខុសត្រូវអ្វីមួយរបស់លោក **អៀង សារី** និងលោក **ខៀវ សំផន** ឡើយ ។ គាត់បានធ្វើការពន្យល់ដូចនេះថា៖

> *នៅក្នុងការងារបក្ស ការអ្នកណា អ្នកនោះដឹង មិនមែនការយើង យើងមិនត្រូវដឹង ។ យើងដឹងតែការណាដែលត្រូវធ្វើ យើងដឹងអ៊ីចឹង ហើយមិនបាច់ទៅសាកសួរគេ មិនបាច់ទៅអឺគេទេ ។ ការណាអ្នកនោះ អ្នកនោះដឹង ។ អានេះ ជាគោលការណ៍សម្ងាត់ ទោះបីជារំដោះហើយក៏ដោយ ក៏នៅតែមានគោលការណ៍សម្ងាត់របស់បក្សដដែល ។ ដូច្នេះ កិច្ចការណាត្រូវដឹង លេខាបក្សគេឲ្យដឹង ក្នុងឋានៈខ្ញុំជាអនុ ឬក៏ជាសមាជិកឯទៀតគេឲ្យដឹង។ ប៉ុន្តែកិច្ចការណាគេឲ្យមិនដឹង ការសម្ងាត់នោះក៏គេមិនឲ្យដឹងដែរ។*[២០]

### *ក.៨. ការបរិយាយរបស់លោក នួន ជា ស្តីអំពីតួនាទីរបស់គាត់ជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា*

លោក **នួន ជា** បានទទួលស្គាល់ថា ខ្លួនជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា ហើយមានឋានៈបន្ទាប់ពីលោក **ប៉ុល ពត** ។ ទោះជាយ៉ាងនេះក្តី គាត់បានទទូចថាគាត់មិនដែលសុំឲ្យគេឲ្យហៅគាត់ថាជាបងធំទីពីរនោះទេ ។ យោងតាមលោក **នួន ជា** ការហៅបែបនេះ គឺជារហស្សនាមដែលកម្មាភិបាល*វៀតណាម*បានផ្តល់នាមនេះឲ្យរូបគាត់ ។ លោក **នួន ជា** បានពោលអះអាងថា នៅពេលគាត់កាន់មុខតំណែងជាអនុលេខាបក្ស គាត់មិនដែលរណបជាអាយ៉ងឲ្យ*វៀតណាម*ឡើយ ។ មិនត្រឹមតែប៉ុណ្ណោះ គាត់បានប្រកាសថា តាំងពី ឆ្នាំ ១៩៦០ *វៀតណាម*គ្មានឥទ្ធិពលត្រួតត្រាលើមាគ៌ាបក្សកុម្មុយនីស្តកម្ពុជាបានទៀតទេ ។

នៅពេលដែលមានសំណួរទាក់ទងនឹងការសរសេរប្រវត្តិរូប ជនជាប់ចោទរូបនេះបានបញ្ជាក់ថា ចាប់ពីទសវត្សរ៍ឆ្នាំ១៩៥០មក រាល់សមាជិកបក្សកុម្មុយនីស្តកម្ពុជាទាំងអស់ តម្រូវឲ្យសរសេរពីប្រវត្តិរូបខ្លួនឯង ដើម្បីកំណត់ពីទស្សនវិស័យ ជំហរដែលប្រឆាំងនឹងមូលធន និងអាចជាការស្រាវជ្រាវនូវទំនាក់ទំនងដែលបុគ្គលទាំងនោះអាចនឹងមានជាមួយសត្រូវ ។ ទោះយ៉ាងណា គាត់បានបដិសេធថាគាត់ពុំមានភារកិច្ចក្នុងការស៊ើបអង្កេត និងសួរចម្លើយមនុស្សតាមរយៈប្រវត្តិរូបរបស់ពួកគេនោះទេ ។

### *ក.៩. មុនពេលការផ្តល់សេចក្តីថ្លែងការណ៍ជាសាធារណៈ*

ភាគីសហព្រះរាជអាជ្ញាបានចោទសួរអំពីបុគ្គលម្នាក់ ឈ្មោះលោក **ខឹម ងន់** ជាមនុស្សម្នាក់ដែលលោក **នួន ជា** បានធ្វើការសន្ទនាជាមួយកាលពីឆ្នាំ១៩៩៨ ។ លោក **នួន ជា** បានផ្តល់សក្ខីកម្មថា គាត់ទុកចិត្ត និងបាននិយាយយ៉ាងស្មោះត្រង់ជាមួយលោក **ខឹម ងន់** អំពីបក្សកុម្មុយនីស្តកម្ពុជា និងចំណុចខ្សោយរបស់

បក្ស ។ ដូចគ្នានេះផងដែរ គាត់បានបញ្ជាក់ថា លោក **ខឹម ងន់** ធ្លាប់បានធ្វើការជាមួយ **តា ម៉ុក** និងធ្វើជាគិញ ឲ្យលោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ផងដែរ ។ បន្ទាប់មក លោកសហព្រះរាជអាជ្ញា **លីសាក់** បានបន្តរៀបរាប់ចំនួនឈ្មោះនៃអ្នកសារព័ត៌មានមួយចំនួនដែលធ្លាប់បានអះអាងថា ពួកគេពីមុនមក ក៏ធ្លាប់បានជួបសម្ភាសន៍ជាមួយលោក **នួន ជា** ដែរ ក៏ប៉ុន្តែជនជាប់ចោទបានធ្វើការអះអាងថា គាត់អាចចងចាំឈ្មោះតែបុគ្គលតែម្នាក់ទេ គឺលោក **ថេត សម្បត្តិ** ។ ជនជាប់ចោទរូបនេះ បានបរិយាយលើចំណុចនេះថា លោក **ថេត សម្បត្តិ** បានធ្វើឲ្យគាត់ទុកចិត្ត ប៉ុន្តែគាត់មិនបានដឹងថាអ្នកសារព័ត៌មានរូបនេះ បានលួចថតវីដេអូរ នូវគ្រប់ពេលកំពុងជជែកគ្នាឡើយ ។ លោក**នួន ជា** បាននិយាយបន្ថែមថា លោក **ថេត សម្បត្តិ** បានរំលោភសិទ្ធិរបស់គាត់នៅក្នុងការផលិតភាពយន្តឯកសារដោយមិនបានជូនដំណឹងដល់គាត់ជាមុន ។

## ខ. ការប្រើប្រាស់សិទ្ធិនៅស្ងៀមរបស់ជនជាប់ចោទ អៀង សារី

ខុសពីលោក **នួន ជា** ដែលបានប្រើប្រាស់ពេលវេលាជាច្រើនក្នុងផ្តល់សក្ខីកម្ម ជនជាប់ចោទ **អៀង សារី** បានប្រើប្រាស់សិទ្ធិមូលដ្ឋានរបស់គាត់ ដោយនៅស្ងៀមស្ងាត់មិនតបទៅនឹងសំណួរដេញដោលណាមួយឡើយ លើកលែងតែសំណួរដែលទាក់ទងនឹងប្រវត្តិរូបផ្ទាល់ខ្លួនរបស់គាត់តែប៉ុណ្ណោះ ។ គាត់បានបញ្ជាក់ថា គាត់មានឈ្មោះពិតថា **គឹម ត្រឹង** កើតនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩២៥ នៅខេត្ត*ត្រាវិញ* កម្ពុជាក្រោម ។ គាត់បានរៀបការជាមួយនឹងអ្នកស្រី **អៀង ធីរិទ្ធ** កាលពីឆ្នាំ១៩៥៣ និងមានកូនស្រីបីនាក់ ហើយប្រុសម្នាក់ ។ ឈ្មោះបដិវត្តន៍របស់គាត់ គឺ**"វ៉ាន់"**។ ក្រៅពីព័ត៌មានលម្អិតខាងលើនេះ លោក **អៀង សារី** បានបដិសេធដោយមិនផ្តល់ព័ត៌មានអ្វីបន្ថែមទៀតឡើយ ។ គាត់បានប្រកាសថា គាត់នឹងមិនផ្តល់សក្ខីកម្មណាមួយឡើយក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីទាំងមូល ។

## គ. សក្ខីកម្មរបស់ជនជាប់ចោទ ខៀវ សំផន

បន្ទាប់ពីបានស្តាប់សក្ខីកម្មរបស់លោក **អៀង សារី** រួចមក អង្គជំនុំជម្រះសាលាដំបូងបានបន្តធ្វើសវនាការដោយស្តាប់សក្ខីកម្មរបស់លោក **ខៀវ សំផន** វិញម្តង ។ ទោះជាយ៉ាងនេះក្តី លោក **ខៀវ សំផន** បានប្រកាសថា គាត់នឹងឆ្លើយតបរាល់សំណួរដេញដោលទាំងអស់ ល្ពឹកណាភាគីព្រះរាជអាជ្ញាបានដាក់បង្ហាញភស្តុតាងចប់សព្វគ្រប់ ។ ក្រោយមកទៀត គាត់បាននិយាយរៀបរាប់ពីខ្សែជីវិតដំបូងរបស់គាត់ និងថែមទាំងបានផ្តល់មតិយោបល់ជុំវិញការចោទប្រកាន់ជាច្រើនមកលើរូបគាត់ក្នុងដីកាដំណោះស្រាយ ។ ដូចគ្នានេះផងដែរ គាត់ក៏បានបន្តការជជែកពិភាក្សាពីទស្សនៈរបស់គាត់ចំពោះប្រវត្តិសាស្ត្រនៃបក្សកុម្មុយនីស្តកម្ពុជា និងតួនាទីរបស់គាត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

### *គ.១. ខ្សែជីវិតដំបូងរបស់ជនជាប់ចោទ ខៀវ សំផន*

យោងតាមលោក **ខៀវ សំផន** បន្ទាប់ពីបានចាកចេញទៅ*ទីក្រុងប៉ារីស* ដើម្បីបន្តការសិក្សាជាន់ខ្ពស់ក្នុងឆ្នាំ១៩៥៣ គាត់បានស្គាល់មិត្តភក្តិម្នាក់ឈ្មោះ **ឱក សុគន្ធ** ហើយមិត្តម្នាក់នេះ បាននិយាយបញ្ចុះបញ្ចូលគាត់ឲ្យចូលរួមក្នុង*រង្វង់ម៉ាក្សស៊ីស* **(the Circle of Marxists)**។ តាមរយៈការបរិយាយពីរឿងរ៉ាវរបស់គាត់ លោក **ខៀវ សំផន** បានចូលរួមក្នុងរង្វង់នេះ ដោយមានជំនឿថា ទិសដៅនៃរង្វង់នេះនឹងនាំមកការយល់ដឹងបានទូលាយដើម្បីជាផ្លូវឈានដល់ការធ្វើឲ្យកម្ពុជាមានឯករាជ្យពីសំណាក់អាណានិគមបារាំង ។ ក្នុងឆ្នាំ១៩៥៥

លោក **ខៀវ សំផន** បានចូលរួមក្នុងបក្សកុម្មុយនីស្តបារាំង ដែលបានលើកទឹកចិត្តប្រជាជនក្នុងស្រុង រួមទាំងប្រជាជនដែលមកពីប្រទេសដែលស្ថិតក្រោមនឹមអាណានិគមដទៃទៀត ឲ្យតស៊ូទាំងអស់គ្នាប្រឆាំងនឹងរបបអាណានិគមនិយម។ គាត់បានបញ្ជាក់ថា គាត់ធ្លាប់បានចូលរួមធ្វើបាតុកម្មគាំទ្រឲ្យមានសង្គ្រាមរបស់ ប្រទេសវៀតណាម និងប្រទេសស៊ីរី ដើម្បីប្រឆាំងនឹងពួកអាណានិគមនិយម ។

នៅពេលដែលលោក **ខៀវ សំផន** បានត្រឡប់មកប្រទេសកម្ពុជាវិញ គាត់បានបង្កើតកាសែតមួយឈ្មោះ *កាសែតឡុបសែរវ៉ាទ័រ* **(L'Observateur)** ជាតំណាងឲ្យសំឡេងរបស់បញ្ញាជន ។ កាសែតនេះ ចេញផ្សាយតែជាភាសាបារាំងមួយគត់ ពីព្រោះគោលដៅរបស់គាត់សំដៅតែទៅលើអ្នកដឹកនាំកម្ពុជាប៉ុណ្ណោះ ដែលពួកគេចូលចិត្តអានតែអត្ថបទជាភាសាបារាំង និងមិនសូវចូលចិត្តកាសែតជាភាសាខ្មែរនោះទេ ។ គាត់បានពន្យល់ថាកាសែតរបស់គាត់មិនគ្រាន់តែមានគោលជំហរគាំទ្រនយោបាយអព្យាក្រឹតរបស់ **សម្តេចនរោត្តម សីហនុ** ប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងជំរុញឲ្យមានវិធានការកែទម្រង់លទ្ធិប្រជាធិបតេយ្យ និងជាស្ពានតភ្ជាប់នូវគំលាតរវាងអ្នកមាន និងអ្នកក្រផងដែរ ។ គាត់បានគូសបញ្ជាក់ថា ចលនាកុម្មុយនីស្តមិនបានឧបត្ថម្ភប្រាក់កាសអ្វីដល់កិច្ចការផ្សាយ*កាសែតឡុបសែរវ៉ាទ័រ* **(L'Observateur)** ឡើយ ក៏ប៉ុន្តែគាត់បានទទួលស្គាល់ថាមានការឧបត្ថម្ភខ្លះៗបានមកពីបុគ្គលអ្នកគាំទ្រកុម្មុយនីស្ត។ ទោះបីជាយ៉ាងនេះក្តី គាត់បានធ្វើការបញ្ជាក់ត្រង់ចំណុចនេះយ៉ាងរហ័សថា អ្នកគាំទ្រលទ្ធិកុម្មុយនីស្តទាំងអ្នកនោះ គឺជាតំណាងរាស្ត្រសភាជាតិមួយចំនួនតែប៉ុណ្ណោះ។ ទោះបីជានៅពេលនោះ គាត់មានការពាក់ព័ន្ធជាមួយនឹងបក្សកុម្មុយនីស្តកម្ពុជាក៏ដោយ លោក **ខៀវ សំផន** បានអះអាងថា **សម្តេច នរោត្តម សីហនុ** បានចាត់ទុកកាសែតរបស់គាត់ជាកាសែត *"ក្រហម"* ក្នុងន័យព្រួយបារម្ភពីគំនិតឯករាជ្យរបស់គាត់ ។ គាត់បានបរិយាយថា បន្ទាប់ពីគាត់បានចេញផ្សាយកាសែតរបស់គាត់បានមួយរយៈមក ក្រសួងនគរបាលពិសេស បានកោះហៅគាត់ទៅសួរចម្លើយ ។ គាត់បាននិយាយប្រាប់ឲ្យដឹងថា ពេលនោះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាអ្នកសួរចម្លើយគាត់ដោយផ្ទាល់ ។ ប្រហែលជាពីរទៅបីខែក្រោយមក គាត់ត្រូវបានគេវាយធ្វើបាប និងចាប់សម្រាតសម្លៀកបំពាក់ចេញ ហើយឲ្យដើរតាមដងផ្លូវទាំងកណ្តាលថ្ងៃត្រង់ ។ លោក **ខៀវ សំផន** បានអះអាងថា នៅពេលក្រោយមកទៀតគាត់ត្រូវបានក្លាយជាមុខសញ្ញានៃការចោទប្រកាន់ដោយពុំមានដីកាណាមួយច្បាស់លាស់ និង ត្រូវបានគេតាមចាប់ខ្លួន ។ ជាងនេះទៅទៀត កាសែតរបស់គាត់ត្រូវគេបិទ ដោយពុំបានដឹងពីមូលហេតុអ្វីឡើយ ។

ក្នុងឆ្នាំ១៩៦២ ជនជាប់ចោទរូបនេះ បានជាប់ឆ្នោតក្លាយជាអ្នកតំណាងរាស្ត្រ ។ ហើយក្រោយមកគាត់ត្រូវបានតែងតាំងជារដ្ឋលេខាធិការនៃក្រសួងពាណិជ្ជកម្មភ្លាមៗ ។ ការបំពេញការងារនៅទីនេះហើយបានផ្តល់ឱកាសឲ្យគាត់ អាចអនុវត្តនូវផែនការកំណែទម្រង់សេដ្ឋកិច្ចដែលជាក្តីសង្ឃឹមទុកក្នុងនិក្ខេបទថ្នាក់បណ្ឌិតរបស់គាត់ ។ លោក **ខៀវ សំផន** បានបញ្ជាក់ថា ព្រះករុណា**សម្តេច នរោត្តម សីហនុ** មិនសព្វព្រះទ័យនឹងសំណើរបស់គាត់ទាក់ទងនឹងផែនការកំណែទម្រង់សេដ្ឋកិច្ចនេះឡើយ ព្រោះមានការរីកចម្រើនតែត្រឹមដើមឆ្នាំដំបូង ក៏ប៉ុន្តែក្រោយមក បានបរាជ័យទៅវិញ ដោយសារតែមានអំពើពុករលួយបានកើតឡើង ។ ជនជាប់ចោទហាក់ដូចប្រាកដក្នុងចិត្តថាដើម្បីកាត់បន្ថយឥទ្ធិពលនយោបាយរបស់គាត់ **សម្តេចនរោត្តម សីហនុ** បានរិះគន់នូវផែនការកំណែទម្រង់របស់គាត់ និងបានលើកទឹកចិត្តឲ្យប្រជាជនឲ្យជឿថា ជនជាប់ចោទគឺជាសមាជិកខ្មែរក្រហម។ ក្រោយមកទៀតគាត់ក៏បានបាត់បង់តំណែងជាតំណាងរាស្ត្រ ។

បន្ទាប់ពីបានរៀបរាប់យ៉ាងលម្អិតពីកិច្ចការពាណិជ្ជកម្មក្រៅប្រទេសនៅសម័យនោះ ជនជាប់ចោទក៏បានបន្តធ្វើការអត្ថាធិប្បាយលើកថាខណ្ឌ ១១២៨ និង១៦០០ នៃដីកាដំណោះស្រាយ ដោយបានលើកឡើង

ពីកាលៈទេសៈដែលគាត់ត្រូវតែភៀសខ្លួនចេញពីភ្នំពេញកាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៦៧ ។ លោក **ខៀវ សំផន** បានអះអាងថា ការភៀសខ្លួនចេញពីភ្នំពេញ ធ្វើឡើងដោយសារតែមានការគំរាមកំហែងផ្នែកសន្តិសុខ ពីព្រោះគាត់ត្រូវបានប្រឈមមុខនឹងការតាមចាប់ខ្លួនពីតុលាការសឹក (តុលាការយោធា) ។ ដោយសារដីកាដំណោះស្រាយមិនបានរៀបរាប់ពីកាលៈទេសៈ ដែលនៅពីក្រោយការភៀសខ្លួនរបស់គាត់ចេញពីទីក្រុងនាពេលនោះ ជនជាប់ចោទរូបនេះ បានការធ្វើបញ្ជាក់យ៉ាងដូច្នេះថា គាត់បានស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ដល់សុវត្ថិភាពផ្ទាល់ខ្លួន គឺដោយសារមានការសង្ស័យដោយគ្មានមូលដ្ឋានថា*កាសែតឡូបសែរវ៉ាទ័រ*របស់គាត់ បានបង្កឲ្យមានការបះបោររបស់កសិករនៅស្រុក*សំឡូត* ។ លោក **ខៀវ សំផន** បានតបតថា មិនអាចទៅរួចទេ ដែលកាសែតរបស់គាត់បានញុះញង់ឲ្យមានការបះបោរ ពីព្រោះកសិករទាំងនោះមិនទាំងចេះអានភាសាបារាំងផង ។

## *គ.២. សមាជិកភាពក្នុងបក្សកុម្មុយនីស្តកម្ពុជា*

លោក **ខៀវ សំផន** បានអះអាងថា សភាពការណ៍ប្រែប្រួលទាំងនេះ បានបង្ខំគាត់ឲ្យចូលរួមជាមួយនឹងបក្សកុម្មុយនីស្តកម្ពុជា ដែលការចូលនេះ គឺធ្វើផ្ទុយពីឆន្ទៈរបស់គាត់ទាំងស្រុង ពីព្រោះគាត់មានទស្សនៈយល់ឃើញខុសគ្នា ។ ជនជាប់ចោទបានធ្វើការបញ្ជាក់ថា គាត់បានទទួលការជ្រោមជ្រែងខ្លះៗ សម្រាប់ធានាផ្នែកសន្តិសុខដល់គាត់ពីថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ជាពិសេសពី **តា ម៉ុក** ។ ដូចអ្វីដែលជនជាប់ចោទបានបញ្ជាក់ខាងលើ គាត់មិនបាននឹកស្មានដល់ទេថា គាត់នឹងចូលរួមជាមួយការតស៊ូបដិវត្តន៍នេះ ។ ម៉្យាងវិញទៀត គាត់ក៏បានទទូចដោយនិយាយថា គាត់មិនពេញចិត្តនឹងលក្ខន្តិកៈ ២យ៉ាង ដើម្បីបានក្លាយជាសមាជិកបក្សកុម្មុយនីស្តកម្ពុជា គឺៈ (១) ត្រូវមានសកម្មភាពប្រយុទ្ធ និង (២) “*ត្រូវមានវណ្ណភាពល្អ*”(សំដៅលើវណ្ណភាពកសិករក្រីក្រ) ។ លោក **ខៀវ សំផន** បានអះអាងថា គាត់មិនធ្លាប់បានធ្វើការតស៊ូអាវុធបានម្តងណាឡើយ ហើយក៏មិនមានវណ្ណភាពជាកសិករក្រីក្រទៀតផង ព្រោះគាត់ជាបញ្ញវន្តជាន់ខ្ពស់ ។ ថ្វីបើគាត់គ្មានជំនឿលើខ្លួនឯងយ៉ាងនេះក្តី បូករួមទាំងការមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលអាចបំពេញតាមល័ក្ខខ័ណ្ឌនៃការចូលជាសមាជិកភាពយ៉ាងណាក៏ដោយ នៅឆ្នាំ១៩៦៩ លោក **ខៀវ សំផន** បានក្លាយជាសមាជិកនៃបក្សកុម្មុយនីស្តកម្ពុជា ។

ជនជាប់ចោទរូបនេះ ក៏បានឆ្លើយបដិសេធចំពោះការចោទប្រកាន់នៅក្នុងកថាខណ្ឌ ១១២៩ នៃដីកាដំណោះស្រាយ ដែលបានលើកឡើងថា គាត់បានជួបជាមួយនឹងលោក **ប៉ុល ពត** លោក **នួន ជា**ក៏ដូចជា ថ្នាក់ដឹកនាំជាន់ខ្ពស់ដទៃទៀត នៅឯទីស្នាក់ការកណ្តាលរបស់បក្សក្នុងអំឡុងពេលនៃការបង្កើត*រណសិរ្សរួបរួមជាតិ* **(National United Front of Kampuchea)** បន្ទាប់ពីការធ្វើរដ្ឋប្រហារទម្លាក់ព្រះមហាក្សត្រ កាលពីឆ្នាំ១៩៧០ ។ គាត់បានទទូចថា “*...មិនមែនខ្ញុំទេ ពីព្រោះខ្ញុំមិនមែននៅក្នុងក្រុមដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាទេ ហើយមិនមែនខ្ញុំទេដែលមកនៅកន្លែងដឹកនាំរបស់បក្សនោះ*”។ ទោះជាយ៉ាងនេះក្តី សេចក្តីថ្លែងការណ៍របស់គាត់ពេលក្រោយមកទៀតបែរជាមានភាពមិនស្របគ្នា ដោយសារវាបានឆ្លុះបង្ហាញឲ្យឃើញថា គាត់ពិតជាមានវត្តមាននៅទីស្នាក់ការកណ្តាលរបស់បក្ស៖

> *គឺ **ប៉ុល ពត** ទេ ដែលហៅខ្ញុំឲ្យទៅទីនោះ ដើម្បីចូលរួមស្តាប់ពេលគាត់ធ្វើការជាមួយកម្មាភិបាលយោធា ដែលមកពីសមរភូមិផ្សេងៗទូទាំងប្រទេសរាយការណ៍ជូនគាត់ និងស្តាប់ការណែនាំ*

*របស់គាត់ទៅឲ្យគេវិញ ។ ស្តាប់ហើយ យល់សភាពការណ៍នៃការតស៊ូវិវត្តន៍ដល់ណាៗហើយ ទើបខ្ញុំអាចសរសេរសេចក្តីរាយការណ៍ថ្វាយសម្តេចបាន ។*[២១]

នៅឆ្នាំដដែលនោះ ក៏មានការបង្កើតរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា **(Royal Government of National Union of Kampuchea)** ដែលរដ្ឋាភិបាលនិរទេសនេះ មានទីស្នាក់ការនៅឯ*ទីក្រុងប៉េងកាំង* រីឯសម្ព័ន្ធភាពរវាង **សម្តេច សីហនុ** និងបក្សកុម្មុយនីស្តកម្ពុជា ក៏ត្រូវបានប្រកាសជាសាធារណៈឡើង ។[២២] លោក **ខៀវ សំផន** មានតួនាទីជាឧបនាយករដ្ឋមន្ត្រី និងក៏ជារដ្ឋមន្ត្រីក្រសួងការពារជាតិក្នុងរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជានេះ ដែលតួនាទីទាំងនេះ គាត់គ្រាន់តែបានឮតាមរយៈការប្រកាសតាមវិទ្យុប៉ុណ្ណោះ ។ គាត់បានថ្លែងម្តងហើយម្តងទៀតថា ទោះបីជាគាត់បានក្លាយជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការពារជាតិជាផ្លូវការក៏ពិតមែន តែតាមភាពជាក់ស្តែង គាត់ពុំមានអំណាចអ្វីឡើយ ហើយក៏មិនមានអង្គភាពណាមួយនៅក្រោមការបង្គាប់របស់គាត់ដែរ ។ គាត់បាននិយាយថា៖ *"ដូចដែលខ្ញុំបានជម្រាបមកនេះ ច្បាស់ហើយគឺ **ប៉ុល ពត** ដែលបានចាត់តាំងខ្ញុំឲ្យទទួលមុខតំណែងដែលខ្ញុំមិនបានដឹងទាល់តែសោះនោះ ជាឧបនាយកខ្យល់ រដ្ឋមន្ត្រីការពារប្រទេសខ្យល់ អគ្គបញ្ជាការខ្យល់"*។[២៣] ជនជាប់ចោទបានយោងនូវអំណះអំណាងនេះដោយបានលើកឡើងថា គាត់គ្មានសិទ្ធិចូលរួមធ្វើសេចក្តីសម្រេចអ្វីទាំងអស់ និងមានភារកិច្ចត្រឹមតែជាអ្នកសរសេរសេចក្តីរាយការណ៍ ដើម្បីភ្ជាប់ទំនាក់ទំនងជាមួយ**សម្តេច នរោត្តម សីហនុ** ក្នុងគោលបំណងបើកផ្លូវឲ្យមានការបង្រួបបង្រួមកម្លាំងជាតិ ។ ដោយយោងតាមគោលគំនិតជាអ្នកដែលបានទទួលការអប់រំខ្ពស់ លោក **ខៀវ សំផន** បាននិយាយបញ្ជាក់ធ្ងន់ៗដោយចោទជាសំណួរថា *"តើនេះជាឧក្រិដ្ឋកម្មឬ? មិនមែនទេ ។ គឺច្បាស់ជាមិនមែនទេ ។"*[២៤]

នៅក្នុងឆ្នាំ១៩៧១ លោក **ខៀវ សំផន** បានក្លាយជាសមាជិកត្រៀមនៃគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ។ ដូចគ្នានឹងតួនាទីក្នុងរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជាដែរ ជនជាប់ចោទរូបនេះ បានអះអាងថា ឋានៈជាសមាជិកត្រៀមក្នុងគណៈមជ្ឈិម គឺគ្រាន់តែធ្វើឡើងឲ្យល្អមើលពីខាងក្រៅប៉ុណ្ណោះ ហើយគាត់គ្មានអំណាចពិតប្រាកដសម្រេចកិច្ចការអ្វីធំដុំឡើយ ។ គាត់បាននិយាយបញ្ជាក់ថា គាត់គ្រាន់តែជាមនុស្សរបស់រណសិរ្ស ហើយគាត់ត្រូវបានគេលើកតម្កើងឲ្យមានឋានៈក្នុងគណៈមជ្ឈិម ដើម្បីការពារកិត្តិយសរបស់គាត់នៅក្នុងជួរបក្សតែប៉ុណ្ណោះ ។ ដើម្បីសបញ្ជាក់ឲ្យឃើញច្បាស់ត្រង់ចំណុចនេះ លោក **ខៀវ សំផន** បានលើកឡើងពីសមាជិកគណៈមជ្ឈិមដទៃទៀតដែលសុទ្ធតែជាអ្នកដែលបានទទួលខុសត្រូវថ្នាក់ភូមិភាគ ឬថ្នាក់តំបន់ ឬអង្គភាពទ័ពធំៗដូចជា ជាមេដឹកនាំកងពលជាដើម ។ ដោយឡែកគាត់វិញ គ្រាន់តែមានភារកិច្ចសរសេរសេចក្តីរាយការណ៍ឲ្យបានញឹកញាប់ទៅព្រះមហាវីរៈក្សត្រតែប៉ុណ្ណោះ ។ គាត់បានបន្ថែមថា គាត់ជាបញ្ញាជន ដូច្នេះហើយគាត់មិនអាចជាមនុស្សរបស់បក្សនោះឡើយ ។

## ឃ. សក្ខីកម្មរបស់សាក្សី ឡុង នរិន្ទ

សប្តាហ៍នេះ អង្គជំនុំជម្រះសាលាដំបូង ភាគីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ភាគីសហព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្តី បានបញ្ចប់ការតាំងសំណួរដេញដោលទៅលើលោក **ឡុង នរិន្ទ** ។ សាក្សីដែលមានវ័យជរារូបនេះបានបន្តបង្ហាញពីភាពស្ទាក់ស្ទើរក្នុងការផ្តល់សក្ខីកម្មនៅក្នុងសវនាការ ។ គាត់បានបង្អើបឲ្យ

ដឹងត្រឹមតែព័ត៌មានតិចតួចមួយចំនួន និងមិនមានលទ្ធភាពចងចាំនូវអង្គហេតុទាំងឡាយ ដើម្បីឆ្លើយតបទៅនឹងសំណួរគន្លឹះមួយចំនួនបានឡើយ ។

### *ឃ.១. ការវិលត្រឡប់មកភ្នំពេញក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុង*

ផ្នែកខ្លះនៃការផ្តល់សក្ខីកម្មរបស់លោក **ឡុង និរិន្ទ** ធ្វើឡើងដោយយោងទៅលើការចងចាំផ្ទាល់របស់គាត់នៅអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីភ្នំពេញ ។ សាក្សីបានផ្តល់សក្ខីកម្មថា គាត់បានប្រទះឃើញប្រជាជនកំពុងដើរនៅតាមដងផ្លូវនៅពេលដែលគាត់បានមកដល់ក្រុងភ្នំពេញនៅថ្ងៃទី២០ ខែមេសា ឆ្នាំ ១៩៧៥ ។ ទោះជាយ៉ាងនេះក្តី សាក្សីមិនបានឆ្លើយតបដោយចំៗទៅនឹងសំណួររបស់លោក **សុន អារុណ** ជាមេធាវីជាតិរបស់លោក **នួន ជា** ដែលបានសួរពីចំនួនប្រជាជនដែលសាក្សីបានឃើញនៅពេលប្រជាជន កំពុងត្រូវបានជម្លៀសចេញនោះ ។ ផ្ទុយមកវិញ សាក្សីបែរជាប្រាប់លោកមេធាវីថា គាត់មិនបានដឹងថាប្រជាជនទាំងនោះកំពុងធ្វើដំណើរទៅទីណាទេ ហើយគាត់ក៏មិនបានសួរនាំចង់ដឹងឮអ្វីឡើយ ពីព្រោះគាត់ថា*“ដឹងច្រើនពេកក៏មានបញ្ហាដែរ”*[២៥]។

ក្រោយពីប្រជាជនទាំងអស់ត្រូវបានជម្លៀសរួចមក លោក **ឡុង និរិន្ទ** បានបម្រើការជាអ្នកវ៉ៃម៉ាស៊ីនអង្គុលីលេខនៅក្នុងក្រសួងការបរទេស (មន្ទីរ*ប-១*)។[២៦] ហើយក្រោយមក គាត់ក៏មានតួនាទីជាកងការពារឲ្យ **សម្តេច សីហនុ** បាន៦ខែ នៅពេលដែលព្រះអង្គនៅគង់ជាគណៈប្រធានរដ្ឋ ។ យោងតាមសាក្សីបាន ឲ្យដឹងថា **សម្តេច សីហនុ** គ្មានអំណាចអ្វីឡើយនៅពេលនោះ ហើយអំណាចទាំងអស់ស្ថិតនៅក្រោមការទទួលខុសត្រូវរបស់លោក **ប៉ុល ពត** និងគណៈមជ្ឈិម ។ប្រសិនបើព្រះអង្គចង់ទៅទតនៅខាងក្រៅ ទ្រង់ត្រូវសុំការអនុញ្ញាតពីគណៈមជ្ឈិមជាមុនសិនដោយធ្វើតាមរយៈអ្នកនាំពាក្យរបស់ទ្រង់ ។ តាមសម្តីរបស់លោក **ឡុង និរិន្ទ សម្តេច** បានលាលែងពីតួនាទីរបស់ទ្រង់នៅដើមឆ្នាំ១៩៧៦ ទោះបីជាមានការសុំអង្វរពីសំណាក់លោក **ខៀវ សំផន** លោក **អៀង សារី** និងសមាជិកគណៈមជ្ឈិមដទៃទៀតយ៉ាងណាក៏ដោយ ។ បន្ទាប់ពីពេលនោះមក ទ្រង់បានយាងទៅកាន់ទីក្រុង*ប៉េកាំង* ដោយឡែកសាក្សី **ឡុង និរិន្ទ** ពេលនោះ បានបន្តស្នាក់នៅកម្ពុជា និងបានវិលត្រឡប់ទៅធ្វើការនៅ*ប-១*វិញដូចដើម ។

### *ឃ.២. ជោគវាសនាបុគ្គលិកដែលបម្រើការនៅក្នុងក្រសួងការបរទេស និងការធ្វើមាតុភូមិនិវត្តន៍របស់ប្រជាជនកម្ពុជា*

សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺកញ្ញា**នូស៊ីន សាការ៉ាទី** **(Ms. Nushin Sarkarati)** បានជួយក្រើនរំឭកសាក្សី ដោយបានដកស្រង់នូវប្រតិចារិកនៃផ្តល់សក្ខីកម្មរបស់គាត់កាលពីសប្តាហ៍មុននេះ និងបានបង្ហាញពីទឡ្ហីករណ៍លើអង្គហេតុ ដែលមានការពាក់ព័ន្ធនឹងបុគ្គលិកបម្រើការក្នុងក្រសួងការបរទេស ស្តីពីការភ័យខ្លាចចំពោះការបញ្ជូនឲ្យទៅ *“រៀនសូត្រ”* ហើយបន្ទាប់មកក៏បាត់ខ្លួនពីក្រសួងជារៀងរហូត ។ ត្រង់ចំណុចនេះ លោក **ឡុង និរិន្ទ** បានអះអាងថា ពាក្យរៀនសូត្រមានន័យថា ជាការទៅធ្វើពលកម្ម ឬជាការបញ្ជូនឲ្យទៅ *ស-២១*ប៉ុន្តែគាត់បានឆ្លើយបដិសេធដោយមិនរៀបរាប់អ្វីបន្ថែមទៀតឡើយ ។ ដូចគ្នានេះផងដែរ លោកសាក្សីបាននិយាយបញ្ជាក់ថាមានអ្នកដែលត្រឡប់មកពីបរទេសវិញតាមការអំពាវនាវរបស់លោក **អៀង សារី** ។ ពួកគេត្រូវបានគេហៅថាជាបញ្ញាវ័ន្ត ហើយអ្នកទាំងនេះ ត្រូវទទួលការលុតដំ*“កសាងខ្លួន”*ត្រូវខិតខំធ្វើការទាំងខាងកម្លាំងពលកម្ម និងបញ្ញា ដើម្បីអាចក្លាយជាអ្នកបដិវត្តន៍បាន ។ លោក **ឡុង និរិន្ទ** បាននិយាយ

បន្តថា អ្នកដែលត្រឡប់មកពីបរទេសទាំងនោះ ត្រូវបានបញ្ជូនទៅធ្វើពលកម្មនៅ*បឹងត្របែក* និង*ច្រាំងចម្រេះ* ដែលជាផ្នែកមួយនៃក្រសួងការបរទេស ។

### *ឃ.៣. សេចក្ដីថ្លែងការណ៍អំពីជនជាប់ចោទ អៀង សារី*

សាក្សី **ឡុង នរិន្ទ** បានអះអាងថា ជាការពិតចំពោះចម្លើយដែលគាត់ធ្លាប់បានផ្ដល់ឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេតកន្លងមក ដោយបានបញ្ជាក់ថាលោក **អៀង សារី** ពិតជាមានអំណាចទាំងស្រុងក្នុងការធ្វើសេចក្ដីសម្រេចអ្វីមួយក្នុងក្រសួងការបរទេស ។ សាក្សីបានពន្យល់ថា នៅពេលណាដែលលោក **អៀង សារី** មិននៅការិយាល័យ*ប-១*ម្ដងៗ គាត់បានដាក់បញ្ជាទៅកាន់អ្នកនៅក្រោមបង្គាប់ថា គ្មាននរណាម្នាក់អាចសម្រេចធ្វើអ្វីមួយដោយគ្មានការអនុញ្ញាតពីគាត់ឡើយ ។ ទោះជាយ៉ាងណាក៏ដោយ សាក្សីបាន បដិសេធពីការដឹងឮដែលថា លោក **អៀង សារី**បានទទួលការណែនាំឲ្យអនុវត្តការងារផ្សេងៗពីគណៈមជ្ឈិម ដែលការឆ្លើយបែបនេះ គឺខុសគ្នានឹងចម្លើយពីមុនរបស់គាត់នៅពេលជួបសម្ភាសន៍ឲ្យខាងការិយាល័យសហចៅក្រមស៊ើបអង្កេត ។ លោក **ឡុង នរិន្ទ** ក៏បានធ្វើអំណះអំណាងផងដែរថា គាត់ពិតជាមិនបានចងចាំថាតើនរណាជាអ្នកប្រាប់គាត់ថា មានម្ដងនោះ ដែលលោក **អៀង សារី** បានប្រកាសក្នុងអង្គប្រជុំថា មិនត្រូវអនុញ្ញាតឲ្យអ្នកណាមកចាប់មនុស្សក្នុងក្រសួងនៅពេលដែលខ្លួន (លោក **អៀង សារី**)មិននៅក្នុងការិយាល័យនៅភ្នំពេញឡើយ ។

### *ឃ.៤. ចលនាបង្រួបបង្រួមជាតិប្រជាធិបតេយ្យ*

នៅក្នុងថ្ងៃទីពីរនៃសវនាការនាសប្ដាហ៍នេះ ចៅក្រម **ឡាវែន៍** បានចោទសួរសំណួរទៅសាក្សី **ឡុង នរិន្ទ** អំពីសេចក្ដីប្រកាសសារព័ត៌មានមួយ ដែលសាក្សីរូបនេះបានរៀបចំឡើងនៅពេលដែលគាត់មានឋានៈជាអគ្គលេខា និងជាអ្នកនាំពាក្យឲ្យចលនាបង្រួបបង្រួមជាតិប្រជាធិបតេយ្យ ហើយដែលក្នុងពេលនោះ សាក្សីជាអ្នកបានជួយធ្វើការបោះផ្សាយឲ្យលោក **អៀង សារី** ក្នុងទសវត្សរ៍ឆ្នាំ១៩៩០ ។ សេចក្ដីប្រកាសព័ត៌មាន ទាំងនោះ គឺភាគច្រើននិយាយពីការរៀបរាប់នូវរឿងរ៉ាវដែលទាក់ទងនឹងលោក **អៀង សារី** ដោយមានទាំងការបញ្ជាក់ថាគាត់មិនដែលធ្លាប់បានដឹងពីការជម្លៀសប្រជាជនចេញពីភ្នំពេញ ហើយក៏មិនដឹងពីបទឧក្រិដ្ឋនានាដែលធ្វើឡើងដោយខ្មែរក្រហមនោះទេ ។ ចៅក្រម **ឡាវែន៍** បានអានកំណត់សម្គាល់មួយក្នុងអត្ថបទដែលបានរៀបរាប់ពីឈ្មោះអ្នកដែលទទួលខុសត្រូវទៅលើអំពើឃោរឃៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ រួមមាន៖ លោក **ប៉ុល ពត** លោក **នួន ជា** លោក **សុន សេន** លោកស្រី **យុន យ៉ាត** និង**តា ម៉ុក**។ សាក្សី **ឡុង នរិន្ទ** បានអះអាងថា គាត់មិនបានចងចាំពីការធ្វើសេចក្ដីប្រកាសសារព័ត៌មានដូចដែលចៅក្រមបានលើកឡើងឡើយ ។

## *ជំពូកទី៣* ៖ **បញ្ហាផ្នែកច្បាប់ និងនីតិវិធី**

អំឡុងពេលនៃសវនាការសប្ដាហ៍នេះ ភាគីទាំងអស់បានលើកឡើងពីបញ្ហាមួយចំនួនដែលភាគច្រើនទាក់ទងទៅនឹងភស្តុតាងជាឯកសារ ។ បញ្ហាទាំងនេះរួមមាន៖ (១) នីតិវិធីសមស្របនៃការដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះ (២) ភាពដែលអាចទទួលយកបាននៃឯកសារ និង (៣) បញ្ហាបកប្រែ និងការធ្វើប្រតិចារឹកដោយការិយាល័យសហចៅក្រមស៊ើបអង្កេតក្នុងពេលធ្វើបទបទសម្ភាសន៍ជាមួយសាក្សី ឬដើមប

ណ្ដឹងរដ្ឋប្បវេណី ។ បញ្ហានីតិវិធីដទៃទៀតមានដូចជាៈ វិសាលភាពនៃតាំងសំណួរដេញដោលទៅលើសាក្សី ឬដើមបណ្ដឹងរដ្ឋប្បវេណី និងវិធានការការពារដែលត្រូវបានយកមកប្រើប្រាស់ដោយ អ.វ.ត.ក ក្នុងការធានាបានថា ទាំងសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីមិនត្រូវបានទទួលរងឥទ្ធិពល ឬការគំរាមកំហែងណាមួយឡើយ ដោយសារអ្នកទាំងអស់នោះត្រូវមកផ្ដល់សក្ខីកម្មក្នុងតុលាការ ។ ចំណុចនេះ ត្រូវបានគេរំពឹងទុកថា បញ្ហាអស់ទាំងនេះ នឹងកើតឡើងជារឿយៗ ជាពិសេសនៅចំពេលដែលអង្គជំនុំជម្រះបានបដិសេធ ដោយមិនធ្វើសេចក្ដីសម្រេចភ្លាមៗទៅលើបញ្ហាទាំងនោះឡើយ ផ្ទុយមកវិញ គ្រាន់តែបានប្រាប់ទៅភាគីទាំងអស់ថា អង្គជំនុំជម្រះនឹងធ្វើសេចក្ដីសម្រេចទៅលើបញ្ហាទាំងអស់នោះ *"នៅពេលដ៏សមគួរឆាប់ៗនេះ"* ។ ចំពោះបញ្ហាមួយចំនួនទៀតដែលត្រូវបានលើកយកមកពិភាក្សាក្នុងសប្ដាហ៍នេះ មានដូចជាៈ ការជូនដំណឹងជាមុនដល់ជនជាប់ចោទស្ដីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងការប្រើប្រាស់សិទ្ធិនៅស្ងៀមរបស់ជនជាប់ចោទ ។

## ក. ការពិចារណាទៅលើភស្តុតាងដែលត្រូវបានដាក់ជូននៅចំពោះមុខអង្គជំនុំជម្រះ

ចំពោះបញ្ហានៃការដាក់ភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ ត្រូវបានលើកឡើងសាជាថ្មីម្ដងទៀតកាលពីថ្ងៃពុធនេះ នៅពេលដែលសហព្រះរាជអាជ្ញាអន្តរជាតិ លោក **ឌេល លីសាក់** បានចាប់ផ្ដើមតាំងសំណួរសួរទៅកាន់លោក **នួន ជា** ដោយបានផ្ដោតទៅលើសៀវភៅមួយដែលមានចំណងជើងថា *នៅពីក្រោយវាលពិឃាដ* និពន្ធដោយលោក **ថេត សម្បត្តិ** ។ នៅពេលនោះ មេធាវីក្រុមការពារក្ដីបានចោទសួរថាតើ សៀវភៅដែលព្រះរាជអាជ្ញាកំពុងតែប្រើយោងក្នុងការតាំងសំណួរនៅចំពោះមុខអង្គជំនុំជម្រះនេះ ត្រូវបានចាត់ទុកជាឯកសារជាភស្តុតាង ឬយ៉ាងណា ។ មេធាវីការពារក្ដីក្រុមផ្សេងទៀត ក៏បានធ្វើការជំទាស់រួមគ្នាទៅលើភាពដែលអាចទទួលយកបាននៃសៀវភៅនេះ ។ លោក **សុន អារុណ**បានលើកឡើងថា អ្នកនិពន្ធសៀវភៅនេះមិនទាន់បានផ្ដល់ការអនុញ្ញាតឲ្យអង្គជំនុំជម្រះប្រើប្រាស់ស្នាដៃនិពន្ធរបស់គាត់ដើម្បីប្រឆាំងនឹងលោក **នួន ជា** នៅឡើយទេ។[២៧] ចំពោះក្រុមមេធាវីប្រឹក្សាក្ដីឲ្យលោក **អៀង សារី** តាមរយៈលោកមេធាវី **ម៉ៃខល កាណាវ៉ាស** (Mr. Michael Karnavas) បានធ្វើការជំទាស់ថា សៀវភៅនេះមិនអាចយកជាការនោះទេ លុះត្រាណាតែអ្នកនិពន្ធមិនបានចូលខ្លួនមកផ្ដល់សក្ខីកម្មក្នុងបន្ទប់សវនាការ ដើម្បីធ្វើការផ្ទៀងផ្ទាត់ពីខ្លឹមសារនៃការសរសេរ និងការដកស្រង់ពាក្យសម្ដីចេញពីសៀវភៅនេះ ផ្ទៀងផ្ទាត់នឹងកិច្ចសន្ទនាជាក់ស្ដែង ជាមួយនឹងជនជាប់ចោទដែលមានរយៈប្រមាណជា ១,០០០ម៉ោង ។ក្នុងការឆ្លើយតបទៅនឹងការជំទាស់ពីសំណាក់ក្រុមមេធាវីការពារក្ដី លោក **លីសាក់** បានលើកឡើងថា ខាងការិយាល័យសហព្រះរាជអាជ្ញា ពិតជាមិនទាន់បានដាក់ជូនឯកសារទាំងនេះនៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងសវនាការនាពេលនេះនៅឡើយទេ ។ គាត់បានស្នើសុំទៅកាន់អង្គជំនុំជម្រះថា ភាគីព្រះរាជអាជ្ញាស្នើប្រើប្រាស់សៀវភៅនេះ គ្រាន់តែជាមធ្យោបាយក្នុងការតាំងសំណួរដោយសួរបញ្ជាក់ពីទំនាក់ទំនងរវាងលោក **នួន ជា** និងអ្នកនិពន្ធសៀវភៅនេះតែប៉ុណ្ណោះ ។ ទោះជាយ៉ាងនេះក្ដី នៅថ្ងៃបន្ទាប់ ភាគីសហព្រះរាជអាជ្ញាបានចោទសួរសំណួរមួយចំនួនដោយផ្អែកលើតែសៀវភៅមួយនេះដដែល ដែលទង្វើនេះបានធ្វើជ្រុលពីការបង្កើតឲ្យឃើញពីទំនាក់ទំនងជាមូលដ្ឋាននៃបទសម្ភាសន៍។ នៅពេលនោះ អង្គចៅក្រមបានក្រើនរំឭកដល់លោក **លីសាក់** ថាមិនត្រូវសម្អាងលើខ្លឹមសារក្នុងសៀវភៅនេះតែមួយមុខបាននោះទេ ដើម្បីធ្វើការតាំងសំណួររបស់ខ្លួន ប្រសិនបើអ្វីដែលកំពុងយោងនេះ មិនទាន់ត្រូវបានដាក់ជូននៅចំពោះមុខអង្គជំនុំជម្រះនៅឡើយ ។ ក្រុមមេធាវីការពារក្ដីវិញ បានទទួលយល់ស្របជាមួយនឹងយោបល់ដែលថា ព្រះរាជអាជ្ញា *"នឹងមិនប្រើប្រាស់សៀវភៅនេះ រហូតដល់តែមានសេចក្ដីសម្រេចត្រូវបានធ្វើឡើង"* ពីអង្គជំនុំជម្រះជាមុន

សិន ។ ការផ្តល់មតិយោបល់នេះ ហាក់ដូចជាបញ្ជាក់ថា ក្រុមមេធាវីការពារក្តីចង់ទាមទារឲ្យអង្គជំនុំជម្រះធ្វើការពិចារណាសម្រេច និងផ្តល់ការអនុញ្ញាតជាមុនសិន ទើបភាគីអាចប្រើប្រាស់បាន ។

ចំពោះការឆ្លើយឆ្លងគ្នាទៅវិញទៅមកនេះ បាននាំឲ្យមេធាវីអន្តរជាតិការពារក្តីឲ្យលោក **ខៀវ សំផន** គឺលោក **អាកទួរ វ៉េកតែន** (Arthur Vercken) ធ្វើការស្នើសុំឲ្យអង្គជំនុំជម្រះចេញនូវវិធានច្បាស់លាស់មួយកំណត់ពីការដាក់ ឬ ប្រើប្រាស់ឯកសារក្នុងអង្គសវនាការ ។ ដើម្បីជាការគាំទ្រដល់ការស្នើសុំរបស់គាត់ លោក **វ៉េកតែន** បានដកស្រង់នូវបញ្ហាជាក់លាក់ពីរ ឬ បីចំណុច ដែលមានទំនាក់ទំនងនឹងភស្តុតាងជាឯកសារៈ (១) សេចក្តីប្រកាសរបស់អង្គជំនុំជម្រះកាលពីសប្តាហ៍មុនថារាល់កំណត់សម្គាល់នៅចុងទំព័រ (footnotes) ក្នុងកថាខណ្ឌនៃដីកាដំណោះស្រាយ ដែលត្រូវបានអានជូនភាគីជាឱឡារិកក្នុងពេលចាប់ផ្តើមដំណើរការនីតិវិធីសវនាការ នឹងត្រូវបានចាត់ទុកថា*“បានដាក់នៅចំពោះមុខអង្គជំនុំជម្រះហើយ”* លើកលែងតែមានការជំទាស់សមហេតុណាមួយពីភាគីនិង (២) នីតិវិធីនៃការដាក់បន្ថែមនូវឯកសារថ្មីៗក្នុងអំឡុងពេលធ្វើសវនាការយោងតាមវិធាន៨៧វិធានផ្ទៃក្នុងនៃអ.វ.ត.ក ។ លោកចៅក្រម **ឡាវ៉ែន** បានឆ្លើយតបដោយនិយាយថា អង្គជំនុំជម្រះទទួលបានសំណើមួយចំនួនពីភាគីស្តីពីឯកសារទាំងឡាយដែលត្រូវបានចាត់ទុកថា បានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ក៏ដូចជាបញ្ហាជាច្រើនទៀតស្តីអំពីភាពអាចទទួលយកបាននៃឯកសារជាក់លាក់មួយចំនួន ។ លោកចៅក្រមបានពន្យល់ថា អង្គជំនុំជម្រះបានកំពុងសិក្សាស្វែងយល់ទៅលើបញ្ហាទាំងអស់នេះ ហើយនឹងធ្វើសេចក្តីសម្រេច *“នៅពេលដ៏សមគួរឆាប់ៗនេះ”* ។ លោកចៅក្រមរូបនេះ បានក្រើនរំឭកដល់ភាគីទាំងអស់ថា អង្គជំនុំជម្រះមានគម្រោងនឹងរៀបចំពេលវេលាឲ្យបានគ្រប់គ្រាន់ក្នុងការបើកឲ្យមានកិច្ចពិភាក្សាពិសេសនៅឆ្នាំថ្មីនេះ ស្តីពីបញ្ហានីតិវិធីដែលពាក់ព័ន្ធនឹងការដាក់បង្ហាញឯកសារ និងភាពអាចទទួលយកបាននៃភស្តុតាងជាឯកសារ ។ នៅចុងបញ្ចប់ លោកចៅក្រម **ឡាវ៉ែន** បានគូសបញ្ជាក់ថា ចំពោះ ព័ត៌មានដែលបានយោងនៅខាងចុងអត្ថបទនោះ ត្រូវបានសន្មតថាអាចយកជាការបាន និងត្រូវបានចាត់ទុកថាបានដាក់បង្ហាញនៅចំពោះមុខអង្គជំនុំជម្រះរួចហើយ ។

បញ្ហាស្តីពីការដាក់បង្ហាញឯកសារនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនេះ គឺដូចគ្នាបេះបិតនឹងបញ្ហាដែលបានកើតឡើងជារឿយៗនៅក្នុងសំណុំរឿងលេខ ០០១ ។ ចំពោះនីតិវិធីក្រោមវិធានផ្ទៃក្នុងលេខ ៨៧(៣) នៃវិសោធនកម្មលើកទី៣[២៨] បានបង្ហាញឲ្យឃើញពី*“បទពិសោធន៍ដដែលៗ និងការប្រើប្រាស់ពេលវេលាច្រើនលើសលុបហួសប្រមាណ”*[២៩]។ ដូច្នេះហើយ នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ បន្ទាប់ពីប្រើប្រាស់ពេលអស់ជាងបីខែក្នុងកិច្ចដំណើរការនីតិវិធីសវនាការរួចមក អ.វ.ត.ក បានរៀបចំកិច្ចប្រជុំស្តីពីការគ្រប់គ្រងសវនាការ ដើម្បីលើកឡើងពីអប្រសិទ្ធភាពនៃដំណើរការនីតិវិធីកន្លងមក ។ កិច្ចប្រជុំនេះ បាននាំឲ្យមានការធ្វើវិសោធនកម្មទៅលើវិធាន ៨៧(៣) ក្នុងចំណោមវិធានមួយចំនួនទៀត ។ ការធ្វើវិសោធនកម្មលើកនេះ បានឆ្លើយតបទៅនឹងការប្រើប្រាស់ភាសាដូចគ្នានៃវិធានផ្ទៃក្នុងដែលទទួលបានពីវិសោធនកម្មលើកទី៨ ដែលកំពុងអនុវត្តក្នុងសំណុំរឿង ០០២ ។វិសោធនកម្មនៃវិធាន ៨៧(៣) បច្ចុប្បន្នបានចែងដូច្នេះថា[៣០]*“ភស្តុតាងដែលមាននៅក្នុងសំណុំរឿង ត្រូវបានចាត់ទុកថាបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះ ឬភាគី បើសិនជាខ្លឹមសាររបស់វាត្រូវបានសង្ខេប ត្រូវបានអាន ឬត្រូវបានកំណត់បង្ហាញអត្តសញ្ញាណយ៉ាងសមស្របក្នុងសវនាការ”* ។ នៅពេលដែលវិសោធនកម្មលើកនេះ បានជួយសម្របសម្រួលដល់ដំណើរការនីតិវិធីនៃការដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះ ការអនុវត្តន៍នៃវិធាន ៨៧(៣) នេះ នៅតែបន្តក្លាយជាកម្មវត្ថុនៃការជជែក

ដេញដោលគ្នា និងបាននាំឲ្យមានការភាន់ច្រឡំឥតឈប់ឈរដោយសារតែទំហំភស្តុតាងជាឯកសារមានចំនួនច្រើនសន្ធឹកសន្ធាប់ពេក ខណៈដែលភាគីត្រូវបានគេរំពឹងទុកថានឹងត្រូវលើកយកឯកសារទាំងនោះមកដាក់បង្ហាញនៅក្នុងកិច្ចដំណើរការនីតិវិធី ។ការមានដំណោះស្រាយច្បាស់លាស់មួយចំពោះបញ្ហារសើបមួយនេះនឹងផ្តល់អត្ថប្រយោជន៍ច្រើនដល់ដំណើរការប្រព្រឹត្តទៅនៃសវនាការជាបន្តបន្ទាប់ទៀតនៃតុលាការ ។

### *ក.១. ការបកប្រែឯកសារ*

បញ្ហាជារួមនៃការដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង គឺជាការបកប្រែឯកសារទាំងអស់នោះជាបីភាសាផ្លូវការដែល ***អ.វ.ត.ក*** អនុញ្ញាតឲ្យប្រើប្រាស់ រួមមានដូចជា៖ ភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង ។ លោកមេធាវី **វែកគែន** បានធ្វើការកត់សម្គាល់ថា មិនមែនសុទ្ធតែឯកសារទាំងអស់ ត្រូវបានបកប្រែជាបីភាសានោះទេ ជាពិសេសឯកសារយោងនៅខាងចុងទំព័រនៃដីកាដំណោះស្រាយដែលឯកសារទាំងនេះ ក៏ត្រូវបានចាត់ទុកថាបានដាក់បង្ហាញនៅចំពោះមុខអង្គជំនុំជម្រះរួចហើយ។ លោក **វែកគែន** បានតវ៉ាថាយោងទៅលើអនុស្សរណៈដែលបានចុះផ្សាយដោយអង្គជំនុំជម្រះ គឺថា រាល់ឯកសារទាំងអស់ដែលត្រូវប្រើប្រាស់នៅក្នុងនីតិវិធីសវនាការ គួរតែត្រូវបានបកប្រែជាបីភាសា។ លោកមេធាវីបានអះអាងបន្ថែមថា បន្ទុកនៃការបកប្រែឯកសារទាំងនេះ មិនគួរជាភារៈរបស់ក្រុមមេធាវីការពារក្តី ឬភាគីដទៃទៀតឡើយ ហើយវាប្រាកដណាស់ដែលការិយាល័យសហចៅក្រមស៊ើបអង្កេតគួរតែបានរៀបចំចាត់ចែងការងារនេះតាំងពីដំបូងទី។ ដើម្បីបញ្ជាក់នូវអំណះអំណាងពីការលើកឡើងរបស់ខ្លួនលោក **វែកគែន** បានដកស្រង់ពាក្យសម្តីចេញពីអនុស្សរណៈដែលចេញផ្សាយដោយអង្គជំនុំជម្រះសាលាដំបូងកាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១១[៣១] ស្តីពីការតម្រូវឲ្យមានការបកប្រែភាសាគ្រប់ឯកសារដែលត្រូវប្រើប្រាស់ក្នុងសវនាការ ។ អ្វីដែលគួរឲ្យកត់សម្គាល់នោះ គឺលោក **វែកគែន** បានដកស្រង់ខ្លឹមសារចេញពីអនុស្សរណៈនេះដូចតទៅ ៖

> *នៅពេលភាគីបង្ហាញឯកសារមួយនៅក្នុងពេលសវនាការ ឯកសារគួរតែប្បីមានជាបីភាសាដែលប្រើប្រាស់ជាផ្លូវការនៅ* ***អ.វ.ត.ក*** *។ ភាគីដែលមានបំណងបង្ហាញឯកសារ មានកាតព្វកិច្ចធ្វើយ៉ាងណាដើម្បីឲ្យឯកសារដែលខ្លួននឹងលើកយកមកបង្ហាញនោះ មានជាបីភាសាផ្លូវការនៅក្នុង* ***អ.វ.ត.ក*** *ឲ្យបានមុនពេលសវនាការ ។*[៣២]

លោកប្រធានអង្គជំនុំជម្រះ បានធ្វើការច្រានចោលនូវការលើកឡើងទាំងនេះ ដោយបញ្ជាក់ថា បញ្ហានៃការបកប្រែភាសាធ្លាប់បានលើកឡើងជាច្រើនលើកមកហើយ ហើយនៅពេលនេះអង្គជំនុំជម្រះនឹងមិនលើកយកមកពិភាក្សាទៀតទេ ។ លោកចៅក្រម **ឡាវែន៍** បានបន្ថែមថា ប្រហែលជាមេធាវីការពារក្តីលោក **ខៀវ សំផន** ដែលទើបតែចូលថ្មីរូបនេះមិនបានដឹងថា កន្លងមក អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចរួច ហើយទាក់ទងនឹងបញ្ហានៃការបកប្រែភាសានេះ ។ លោកចៅក្រមបានណែនាំលោកមេធាវីថា មិនមានចំណុចណាមួយនៃសេចក្តីសម្រេចពីមុននោះ ដែលតុលាការបានសម្រេចថា រាល់ឯកសារទាំងអស់ត្រូវតែធ្វើការ បកប្រែជាបីភាសាដើម្បីឲ្យឯកសារនោះអាចក្លាយជាឯកសារភស្តុតាងនោះទេ ។

បញ្ហានៃការបកប្រែឯកសារជាបីភាសាផ្លូវការក្នុងសវនាការ បានទាញការចាប់អារម្មណ៍ជាថ្មីម្តងទៀតពីសាធារណជន នៅពេលដែលក្រុមមេធាវីការពារក្តីឲ្យលោក **អៀង សារី** បានលើកឡើងពីប្រតិចារឹកនៃបទ

សម្ភាសន៍ដែលប្រើប្រាស់តែភាសាខ្មែរមួយប៉ុណ្ណោះ។ ប្រតិចារិកនេះ ត្រូវបានធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ។ បញ្ហានេះ ត្រូវបានលោក **កាណាវ៉ាស** កត់សម្គាល់ថា ជាការដែលអាចបណ្តាលឲ្យមានបញ្ហាមួយចំនួនដល់ភាគីការពារក្តីអន្តរជាតិ និងចៅក្រមជំនុំជម្រះអន្តរជាតិ ដែលពុំមានលទ្ធភាពគ្រប់គ្រាន់ ក្នុងស្វែងយល់ពីសេចក្តីសង្ខេបជាលាយលក្ខណ៍អក្សរចំពោះលទ្ធផលដែលរៀបចំឡើងពីការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយក៏មិនអាចធ្វើការត្រួតពិនិត្យយថាភាពនៃប្រតិចារឹកទាំងនោះបានដែរ ។ ជាថ្មីម្តងទៀត អង្គជំនុំជម្រះសាលាដំបូងបានធានាចំពោះភាគីទាំងអស់ថា អង្គជំនុំជម្រះនឹងត្រូវធ្វើសេចក្តីសម្រេចលើបញ្ហាទាំងអស់នេះក្នុងពេលដ៏សមគួរមួយតាមដែលអាចធ្វើទៅបាន ។

### *ក.២. យថាភាពនៃឯកសារ*

កាលពីថ្ងៃព្រហស្បតិ៍បន្ទាប់ពីបានសម្រាកទទួលទានអាហារថ្ងៃត្រង់រួចមក សហព្រះរាជអាជ្ញា លោក **លីសាក់** មានបំណងចង់បានព័ត៌មានលម្អិតដោយបានស្នើលោក **នួន ជា**ឲ្យផ្តល់យោបល់លើសុន្ទរកថារបស់លោក **ប៉ុល ពត** ដែលត្រូវបានដកស្រង់ចេញពីការផ្សព្វផ្សាយនៃទស្សនាវដ្តី*ទង់បដិវត្តន៍* នៅឆ្នាំ១៩៧៧ ។ ទោះជាយ៉ាងនេះក្តី ជំនួសឲ្យការឆ្លើយតបទៅនឹងអង្គហេតុដែលព្រះរាជអាជ្ញាបានចោទសួរនោះ លោក **នួន ជា** បានទាមទារម្តងហើយម្តងទៀត ឲ្យផ្តល់ទស្សនាវដ្តីច្បាប់ដើមឲ្យគាត់ពិនិត្យមើលជាមុនសិនទើបគាត់អាចធ្វើការឆ្លើយតបនឹងសំណួរនេះបាន ។ លោក **លីសាក់** បានក្រើនរំឭកជនជាប់ចោទរូបនេះថា ក្រុមមេធាវីការពារក្តី មិនបានធ្វើការជំទាស់នឹងការប្រើប្រាស់ឯកសារថតចម្លងនេះទេ នៅពេលដែលលោកស្រីចៅក្រម **ខាតវ៉ាយថ៍** បានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះកាលពីពេលកន្លងទៅ ។ លោកប្រធានអង្គជំនុំជម្រះ **និល ណុន** បានពន្យល់ថា គ្រប់ឯកសារទាំងអស់ត្រូវបានរៀបចំដាក់បញ្ចូលក្នុងប្រព័ន្ធកុំព្យូទ័រ ដោយសារតែបរិមាណឯកសារដ៏ច្រើនលើសលប់នៅក្នុងសំណុំរឿងនាពេលបច្ចុប្បន្ននេះ ។ ប្រធានតុលាការ បានបន្ថែមទៀតថា ឯកសារទាំងនេះត្រូវបានលើកយកមកប្រើជាសម្អាងតាំងពីដំណាក់កាលស៊ើបអង្កេតមកម្ល៉េះ ហើយតាមពេលវេលាដ៏វែងឆ្ងាយនេះ ក្រុមមេធាវីការពារក្តីគួរតែលើកឡើងពីការជំទាស់ណាមួយ ដែលពួកគេមាននៅពេលដែលដីកាដំណោះស្រាយត្រូវបានចេញផ្សាយ ។ មេធាវីអន្តរជាតិការពារក្តីឲ្យលោក **នួន ជា** គឺលោក **ម៉ៃខល ផេស្តមិន** (Mr. Michiel Pestman) បានក្រោកឈរដើម្បីគូសបញ្ជាក់ពីគោលជំហរកូនក្តីខ្លួនចំពោះបញ្ហានេះ ដោយតវ៉ាថា ការព្រួយបារម្ភរបស់លោក **នួន ជា** គឺបញ្ហាទាក់ទងនឹងយថាភាពនៃឯកសារ ហើយកូនក្តីខ្លួនមិនមែនដេញដោលអំពីថាតើឯកសារដែលបានប្រើដើម្បីតាំងសំណួរលើគាត់ជាឯកសារ ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះហើយឬនៅនោះទេ ។ សហព្រះរាជអាជ្ញាអន្តរជាតិ លោក **វីល្លៀម ស្មីត** (Mr. William Smith) បានតបវិញថា បញ្ហាស្តីអំពីថាតើយថាភាពនៃឯកសារមួយ ត្រូវមានធាតុរួមផ្សំអ្វីខ្លះ គឺវាអាស្រ័យទាំងស្រុងទៅលើករណីអង្គហេតុដែលមាននៅឯកសារ ហើយមិនមានមូលដ្ឋានណាមួយ ដែលតុលាការមិនត្រូវប្រើឯកសារច្បាប់ថតចម្លងនោះទេ លើកលែងតែការជំទាស់នោះឆ្លុះបញ្ចាំងឲ្យឃើញថាឯកសារថតចម្លងណាមួយនោះ វាខុសពីអ្វីដែលមាននៅក្នុងច្បាប់ដើម ។ គាត់បានបន្ថែមទៀតថា តុលាការអន្តរជាតិមួយចំនួន បានទទួលយកឯកសារថតចម្លងទៅប្រើប្រាស់ដោយសារទំហំដ៏ច្រើននៃឯកសារជាភស្តុតាងដែលត្រូវយកមកធ្វើការពិភាក្សាសួរដេញដោលទៅលើករណីនីមួយៗ ។

ជាថ្មីម្តងទៀត អង្គជំនុំជម្រះ បានឆ្លើយតបទៅនឹងការជំទាស់ជាច្រើនដែលបានលើកឡើងដោយភាគី ហើយក៏បានសន្យាផងដែរថា នឹងពិភាក្សាសម្រេចលើការជំទាស់ទាំងអស់នោះ ហើយផ្សព្វផ្សាយនូវការ

សម្រេចនោះជាបន្តបន្ទាប់ក្នុងពេលសមស្របឆាប់ៗនេះ។ អង្គជំនុំជម្រះ ក៏បានថ្លែងសាជាថ្មីថា អង្គជំនុំជម្រះបានលៃលកទុកពេលវេលាមួយសប្តាហ៍នៃកិច្ចដំណើរការនីតិវិធីនៅក្នុងខែមករា ដើម្បីពិភាក្សាទៅលើការដាក់សំណើនានា ភាពអាចទទួលយកបាននៃឯកសារក៏ដូចជាយថាភាពនៃភស្តុតាងជាឯកសារ ដើម្បីរកដោះស្រាយបញ្ចប់នូវបញ្ហាប្រឈមមួយចំនួនដែលបានកើតឡើងជារឿយៗ នៅក្នុងដំណើរការនីតិវិធីសវនាការ ។

### *ក.៣. នីតិវិធីធ្វើកំណត់ហេតុនៅអំឡុងពេលនៃការស៊ើបសួររបស់បុគ្គលិកការិយាល័យសហចៅក្រមស៊ើបអង្កេត*

អនុលោមតាមវិធាន ៥៥.៥(ក) និង វិធាន ៦០.១ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក សហចៅក្រមស៊ើបអង្កេត អាចសួរចម្លើយ ធ្វើការកត់ត្រា ឬថតសំឡេង និងអាចស្តាប់ចម្លើយសារភាពពីជនទាំងឡាយណា ដែលខ្លួនយល់ឃើញថា សក្ខីកម្មរបស់ពួកគេមានសារៈប្រយោជន៍ក្នុងការស្វែងរកការពិត ។ តាមវិធាន ២៥.១(ឃ) ផ្តល់ឱកាសឲ្យសាក្សីធ្វើការបញ្ជាក់ឡើងវិញនូវចម្លើយនានារបស់ខ្លួននៅចុងបញ្ចប់នៃការផ្តល់ចម្លើយ។ ការធ្វើកំណត់ត្រាជាលាយលក្ខណ៍អក្សរដែលបានពីការស្តាប់ចម្លើយ គួរតែត្រូវបានចុះហត្ថលេខា ឬ ផ្តិតមេដៃទទួលស្គាល់ បន្ទាប់ពីសាក្សីបានអានចម្លើយរបស់ខ្លួនចប់ ។[៣៣] ទោះជាយ៉ាងនេះក្តីមិនមានគោលការណ៍ណែនាំច្បាស់លាស់ណាមួយបានចែងនៅក្នុងវិធានផ្ទៃក្នុងរបស់អ.វ.ត.កទេហើយក៏ពុំមានការសម្រេចណាមួយលើបញ្ហានេះពីអង្គជំនុំជម្រះសាលាដំបូងតាំងពីសំណុំរឿង០០១មកម្ល៉េះ ស្តីពីវិធីសាស្រ្ត ក៏ដូចជាវិសាលភាពនៃការស្តាប់ចម្លើយដែលធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ។

នៅពេលចាប់ផ្តើមតាំងសំណួរដេញដោលទៅលើសាក្សី **ឡុង នរិន្ទ** ដោយលោក **អាង ឧត្តម** ជាមេធាវីជាតិការពារក្តីឲ្យលោក **អៀង សារី** មេធាវីរូបនេះបានទាញការចាប់អារម្មណ៍ពីសំណាក់អង្គជំនុំជម្រះជុំវិញភាពមិនស៊ីចង្វាក់គ្នារវាងប្រតិចារឹកនៃខ្សែអាត់ថ៍ថតសំឡេង និង កំណត់ត្រាជាលាយលក្ខណ៍អក្សរនៃបទសម្ភាសន៍របស់សាក្សីដែលរៀបចំឡើងដោយបុគ្គលិកមកពីការិយាល័យសហចៅក្រមស៊ើបអង្កេត។ មេធាវីក៏បានចង្អុលបង្ហាញនូវភាពមិនប្រក្រតីមួយចំនួនទៀត ដែលអ្នកបកប្រែភាសាបានជួយអន្តរាគមន៍ (ថែមថយពាក្យសម្តី) ដើម្បីទទួលបានចម្លើយមួយចំនួនពីសាក្សីក្នុងអំឡុងពេលនៃការធ្វើបទសម្ភាសន៍ផងដែរ ។ នៅពេលដែលលោក **កាណាវ៉ាស** បានធ្វើការជជីកសួរសាក្សី **ឡុង នរិន្ទ** ដើម្បីបង្ហាញពីភាពអាចជឿជាក់បាននៃសក្ខីកម្មរបស់គាត់ សាក្សីរូបនេះបានទម្លាយឲ្យដឹងថា គាត់មិនត្រូវបានគេផ្តល់ឱកាសឲ្យអានប្រតិចារឹក ឬធ្វើការផ្ទៀងផ្ទាត់ទៅលើឯកសារទាំងបីប្រភេទដូចដែលបាននឹងកំពុងលើកឡើងក្នុងបន្ទប់សវនាការនេះទេ (ប្រតិចារឹកជាសំឡេង កត់ត្រាដោយដៃ និងប្រតិចារឹកសង្ខេបដោយប្រើកំព្យូទ័រ) ។ ទោះជាយ៉ាងនេះក្តីតាម ការសួរបញ្ជាក់ពីសំណាក់ចៅក្រម **ឡាវែន៍** សាក្សី **ឡុង នរិន្ទ** បានអះអាងថា គាត់ពិតជាបានផ្តល់ហត្ថលេខា និងផ្តិតស្នាមមេដៃដោយស្ម័គ្រចិត្តទៅលើកំណត់ត្រាជាលាយលក្ខណ៍អក្សរទាំងនោះមែន តែបានអះអាងថា គាត់ចាំមិនបានទេថាមានគេអានកំណត់ត្រានោះឲ្យគាត់ស្តាប់ម្តងទៀត ហើយក៏មិនអាចបញ្ជាក់បានថាតើ កំណត់ត្រានោះ គួរទុកចិត្តបានកម្រិតណាទេ ប្រៀបធៀបនឹងចម្លើយដែលគាត់បានផ្តល់ជូនការិយាល័យសហចៅក្រមស៊ើបអង្កេតនាពេលនោះ ។

ចម្លើយមួយចំនួនរបស់សាក្សីទាក់ទងនឹងប្រធានបទនេះ នាំឲ្យលោក **កាណាវ៉ាស** បានធ្វើការតវ៉ាថា កំណត់ត្រាជាលាយលក្ខណ៍អក្សរនេះ មិនបានឆ្លុះបញ្ចាំងនូវភាពស្របគ្នាជាមួយនឹងចម្លើយពិតរបស់លោក

**ឡុង នរិទ្ធ** ទាំងអស់នោះទេ ។ គាត់បានផ្តល់យោបល់ថា វាអាចទៅរួចដែលមន្ត្រីផ្នែកស៊ើបសួរ ជួយធ្វើការសម្រួលដល់សាក្សីដើម្បីឲ្យបានចម្លើយដែលពួកគេចង់បាន ឬ ន័យមួយទៀតគឺគេអាចនឹងថ្លែងរៀបរាប់ដូចប្រាប់រឿងរ៉ាវឲ្យសាក្សីស្តាប់ ហើយក្រោយពីស្តាប់ហើយ សាក្សីគ្រាន់តែជួយឆ្លើយបញ្ជាក់ ពោលគឺវាហាក់ដូចជាការបញ្ចុកចំណីដូច្នោះដែរ ។ លោក **កាណាវ៉ាស** បានលើកឡើងពីការព្រួយបារម្ភខ្លាំងលើបញ្ហានេះ ដោយសារតែភាគីនឹងត្រូវចំណាយពេលដោះស្រាយ និងជជែកវែកញែកលើសេចក្តីសង្ខេបដែល*"មិនអាចជឿជាក់បាន"*[៣៤] ទាំងនេះ នៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីតុលាការមិនចប់មិនហើយ ។ ដោយមានការព្រមព្រៀងគ្នាជាមួយភាគីសហព្រះរាជអាជ្ញា លោក **កាណាវ៉ាស** បានស្នើទៅកាន់អង្គជំនុំជម្រះឲ្យចាត់ចែងធ្វើកំណត់ត្រាទាំងស្រុងនូវប្រតិចារឹកនៃការសម្ភាសន៍ជាសំឡេង និងធ្វើការបកប្រែជាភាសាផ្លូវការរបស់តុលាការ ដែលការធ្វើដូច្នេះ ជាប្រយោជន៍ឲ្យភាគីអាចផ្ទៀងផ្ទាត់ថាតើចម្លើយទាំងឡាយមានភាពស្រប ឬ មិនស្របដូចម្តេចខ្លះ ។ អង្គជំនុំជម្រះបានធានាអះអាងចំពោះភាគីថា អង្គជំនុំជម្រះនឹងចេញអនុស្សរណៈដោះស្រាយលើបញ្ហាទាំងអស់នេះក្នុងពេលដ៏សមគួរឆាប់ៗនេះ ។

### *ក.៤. សំណួរដែលមិនត្រូវបានអនុញ្ញាតឲ្យធ្វើការសួរដេញដោល*

នាសប្តាហ៍នេះ ភាគីទាំងអស់បានលើកឡើងនូវការជំទាស់មួយចំនួនស្តីពីបែបបទនៃការតាំងសំណួរដេញដោលទាំងលើជនជាប់ចោទ និងសាក្សី ។ ជាឧទាហរណ៍នៅព្រឹកថ្ងៃព្រហស្បតិ៍នេះ លោក **ផេស្គមិន** បានតាំងសំណួរដេញដោលទៅលើលោក **ឡុង នរិទ្ធ** ទាក់ទងនឹងមូលហេតុដែលសាក្សីរូបនេះ មិនបានលើកឡើងពីលោក **គាត ឈន់** ក្នុងសក្ខីកម្មរបស់គាត់ ផ្ទុយពីកំណត់ត្រាចម្លើយរបស់គាត់ផ្តល់ឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលបានរម្លឹកពីបុគ្គលម្នាក់នេះជាច្រើនលើកច្រើនសា។ លោក **ផេស្គមិន** បានផ្ទៀងសាក្សីថា ប្រហែលជាអាចដែលសាក្សីទទួលរងសម្ពាធណាមួយនៅក្នុងការធ្វើសក្ខីកម្មរបស់គាត់ក្នុងសវនាការនាពេលនេះ ឬវាអាចប្រហែលជាមកពីគាត់បានដឹងពីឋានៈរបស់លោក **គាត ឈន់** នៅក្នុងជួររាជរដ្ឋាភិបាលកម្ពុជានាពេលបច្ចុប្បន្ន ដែលប្រការនេះ អាចជាមូលហេតុដែលពេលក្រោយមកទៀត សាក្សី បដិសេធលែងចង់ផ្តល់សក្ខីកម្ម។ ត្រង់ចំណុចនេះ លោក **ឡុង នរិទ្ធ** បានឆ្លើយតបថា មិនមាននរណាម្នាក់បានបញ្ចុះបញ្ចូលគាត់ហើយគាត់ក៏មិនបានរងសម្ពាធណាមួយមុននឹងមកផ្តល់សក្ខីកម្មនាពេលនេះដែរ ។ សាក្សីបានបន្ថែមថាគាត់មិនបានដឹងពីមុខតំណែងរបស់លោក **គាត ឈន់** នៅក្នុងជួររាជរដ្ឋាភិបាលនាពេលបច្ចុប្បន្នឡើយ។[៣៥] ប្រធានអង្គជំនុំជម្រះ ចៅក្រម **និល ណុន** មិនបានអនុញ្ញាតឲ្យសួរសំណួរបន្ថែមចំពោះប្រធានបទនេះឡើយ ដោយលើកហេតុផលថាជាសំណួរមិនពាក់ព័ន្ធ និងមានលក្ខណៈផ្ទុយពីគោលការណ៍នៃការតាំងសំណួររបស់តុលាការហើយក៏មិនត្រូវនឹងអង្គហេតុដែលមានចែងក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះផងដែរ ។ ចំពោះក្រុមមេធាវីការពារក្តីឲ្យលោក **នួន ជា** វិញ បានបដិសេធនឹងសេចក្តីសម្រេចនេះ ដោយធ្វើការអះអាងថា *"ជំហររបស់មេធាវីការពារក្តី គឺថាសំណួរទាំងឡាយទាក់ទងនឹងការជ្រៀតជ្រែកនយោបាយ គឺសុទ្ធតែជាសំណួរពាក់ព័ន្ធទៅនឹងគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធីទាំងអស់"*។[៣៦] ចៅក្រម **ស៊ីលវៀ ខាតវ៉ាយថ៍** បានធ្វើការកត់សម្គាល់ទៅលើការជំទាស់នេះ តែមិនបានធ្វើសេចក្តីសម្រេចអ្វីឡើយ ។ លោកស្រីគ្រាន់តែបានថ្លែងថា "ការជំទាស់របស់លោកមេធាវីត្រូវបានកត់ត្រាហើយ ហើយអង្គជំនុំជម្រះនឹងត្រូវដោះស្រាយបញ្ហានេះឲ្យបានសមស្រប"។

នៅរសៀលថ្ងៃព្រហស្បតិ៍ ភាគីសហព្រះរាជអាជ្ញាបានតាំងសំណួរដេញដោលទៅលើលោក **នួន ជា** ក្នុងគោលបំណងលើកបង្ហាញថា ព្រះពុទ្ធសាសនាមិនត្រូវបានទទួលស្គាល់ដោយលទ្ធិកុម្មុយនីស្តទេ ហើយមិនត្រឹមតែប៉ុណ្ណោះដោយសារមានគោលការណ៍មិនស្របគ្នា បក្សកុម្មុយនីស្តកម្ពុជាបានហាមឃាត់មិនឲ្យមានការគោរពប្រតិបត្តិព្រះពុទ្ធសាសនាក្នុងប្រទេសឡើយ ។ ការជំទាស់របស់លោក **កាណាវ៉ាស** ទៅលើការតាំងសំណួរបែបនេះត្រូវបានសម្រេចថាជាការសមស្រប ដោយសារតែប្រធានបទនេះ មិនមានភាពពាក់ព័ន្ធគ្នា និងនៅក្រៅវិសាលភាពនៃវគ្គទី១នៃសវនាការនេះ ។ ត្រង់ចំណុចនេះ លោក **លីសាក់** បានតវ៉ាថា សំណួររបស់គាត់ចង់បង្ហាញឲ្យឃើញពីគោលការណ៍របស់បក្សកុម្មុយនីស្តក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ដែលជាអំឡុងពេលដែលព្រះសង្ឃត្រូវបានចាត់ទុកថាជាសត្រូវរបស់បក្សកុម្មុយនីស្ត ។ ក្រុមមេធាវីការពារក្ដីបានស្នើ ថា ការតវ៉ារបស់សហព្រះរាជអាជ្ញា គឺជាការបញ្ឆោតមតិ បដិសេធនូវការពិត និង ដើម្បីបំប៉ោងទៅលើបញ្ហាយថាភាពនៃសុន្ទរកថារបស់លោក **ប៉ុល ពត** នៅពេលត្រូវដកស្រង់មកសួរសំណួរ ។ ប្រការនេះ បាននាំឲ្យមានការជំទាស់ផ្សេងទៀតពីសំណាក់លោក **កាណាវ៉ាស** ដោយគាត់បានទាមទារថា ស្ថាប័នអយ្យការកំពុងឆ្លើយដោះសាចំពោះការចោទប្រកាន់នេះ ហើយជាការគួរដែលព្រះរាជអាជ្ញាត្រូវកម្រិតនូវការសួរសំណួររបៀប នោះ ។ អង្គជំនុំជម្រះបានយល់ស្របតាមនូវការជំទាស់ដែលធ្វើឡើយដោយលោក **កាណាវ៉ាស** ។ ពេញមួយសប្ដាហ៍នេះ មានសេចក្ដីជំទាស់មួយចំនួនផ្សេងទៀត ត្រូវបានលើកឡើងដោយភាគី រួមមានបញ្ហានៃការសួរសំណួរដែលមានលក្ខណៈដឹកមុខ សំណួរដែលគ្មានភាពពាក់ព័ន្ធគ្នាក្នុងសំណុំរឿង សំណួរដែលនាំឲ្យមានការឆ្លើយដោយស្មានៗ ឬក្រៅបរិបទនៃសំណុំរឿង ។

យើងមើលឃើញថាបញ្ហាទាំងនេះអាចនឹងនៅតែបន្តកើតមាន ដូច្នេះវានឹងមានប្រយោជន៍ច្រើន ក្នុងការដែលអង្គជំនុំជម្រះផ្ដល់នូវគោលការណ៍ការណែនាំច្បាស់លាស់ផ្សេងៗ ដើម្បីដោះស្រាយឲ្យឆ្លើយតបនឹងកង្វល់ស្ដីពីវិសាលភាពនៃសំណួរ ថាតើមានប្រភេទណាខ្លះដែលត្រូវអនុញ្ញាតឲ្យភាគីធ្វើការតាំងសំណួរដេញដោលលើសាក្សី ឬបុគ្គលទាំងឡាយណាដែលត្រូវបានកោះហៅឲ្យមកផ្ដល់សក្ខីកម្មជាភស្តុតាង។

### *ក.៥. ការណែនាំជនជាប់ចោទឲ្យយល់ដឹងពីសិទ្ធិរបស់ពួកគាត់ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌*

ជាទូទៅ ប្រធានតុលាការ ជាអ្នកចាប់ផ្ដើមការសួរនាំអំពីអត្តសញ្ញាណបុគ្គល និងប្រវត្តិរូប មិនថាទៅលើសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី ឬជនជាប់ចោទ ហើយបន្ទាប់មកណែនាំពីសិទ្ធិរបស់ពួកគេដាច់ដោយឡែកពីគ្នា មុនពេលប្រគល់នាទីសួរដេញដោលលម្អិតដោយភាគីផ្សេងៗទៀត ។ សប្ដាហ៍នេះ បន្ទាប់លោកប្រធានអង្គជំនុំជម្រះសាលាដំបូង បានធ្វើការពន្យល់ណែនាំជាផ្លូវការដល់ជនជាប់ចោទ លោក **ខៀវ សំផន** និងលោក **អៀង សារី** ពីសិទ្ធិរបស់ពួកគាត់មានដូចជា៖ ការទទួលបានការការពារក្ដីដោយមានមេធាវីតាមការពេញចិត្តនៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី ការទទួលបានសិទ្ធិនៅស្ងៀម និងសិទ្ធិក្នុងការឆ្លើយមិនដាក់ពិរុទ្ធភាពលើខ្លួនឯងនៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី ហើយនិងសិទ្ធិទទួលបានព័ត៌មាននៃបទចោទប្រកាន់ប្រឆាំងនឹងពួកគាត់ ។ ត្រង់ចំណុចនេះ លោកប្រធាន **និល ណុន** បានសួរបញ្ជាក់ថាតើពួកគាត់បានយល់ដឹងពីបទចោទប្រកាន់ទៅលើពួកគាត់ដែរឬអត់ បន្ទាប់មក លោកប្រធានបានសុំឲ្យពួកគាត់ធ្វើការបញ្ជាក់ពីបទចោទប្រកាន់នេះជូនដល់អង្គជំនុំជម្រះ។ កិច្ចដំណើរការនេះ មានសារៈសំខាន់ណាស់នៅគ្រប់កិច្ច

ដំណើរការនីតិវិធីព្រហ្មទណ្ឌក្នុងការធានាថា បុគ្គលទាំងឡាយដែលនឹងត្រូវធ្វើការជំនុំជម្រះ ត្រូវតែយល់ដឹងពីបទចោទប្រកាន់មកលើខ្លួនគាត់ និងមានការយល់ដឹងពីសិទ្ធិរបស់គាត់ក្នុងនាមជាជនជាប់ចោទ ។

### *ក.៦. សិទ្ធិនៅស្ងៀមមិនឆ្លើយតប*

សិទ្ធិនៅស្ងៀម និងសិទ្ធិមិនឆ្លើយដាក់ពិរុទ្ធភាពប្រឆាំងលើខ្លួនឯង គឺត្រូវបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុងនៃ **អ.វ.ត.ក** និងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។ ដូច្នេះ ជនជាប់ចោទត្រូវទទួលបាននូវការគោរពពីសិទ្ធិទាំងនេះ ដើម្បីធានាពីការគោរពនូវបទដ្ឋាននៃការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលបានបង្គាប់បញ្ញាយ៉ាងច្បាស់លាស់នៅក្នុងច្បាប់ទាំងឡាយដូចបានរៀបរាប់ខាងដើម ។ ទោះជាយ៉ាងនេះក្តី មានសំណួរចោទឡើងមួយចំនួន ដែលមិនទាន់មានការឆ្លើយតបស្តីអំពីថាតើមាននីតិវិធីជាក់ស្តែងអ្វីខ្លះ ឬការអនុវត្តជាវិជ្ជមានណាខ្លះដើម្បីឲ្យឆ្លើយតបទៅនឹងការប្រើប្រាស់សិទ្ធិទាំងនោះនៅចំពោះមុខតុលាការ ។

នៅរសៀលថ្ងៃច័ន្ទ បន្ទាប់ពីត្រូវបានកោះហៅឲ្យចូលខ្លួនក្នុងសវនាការ ជនជាប់ចោទ **អៀង សារី** បានប្រើប្រាស់សិទ្ធិនៅស្ងៀមរបស់គាត់នៅក្នុងអំឡុងពេលពេញមួយកិច្ចដំណើរការនីតិវិធី ។ បន្ថែមពីនេះ មេធាវី **កាណាវាស** បានស្នើសុំឲ្យអង្គជំនុំជម្រះបញ្ឈប់ការសួរសំណួរដេញដោលទៅលើលោក **អៀង សារី** ព្រោះថាកូនក្តីរបស់គាត់មានបំណងនឹងប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបនឹងសំណួរណាមួយនោះឡើយ នៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធីសវនាការ ឬការជំនុំជម្រះក្រោយៗទៀត ដូចមានលើកឡើងក្នុងដីកាដំណោះស្រាយ ។ យោងតាមការលើកឡើងនេះ លោកមេធាវីបានស្នើសុំអង្គជំនុំជម្រះមិនឲ្យនាំខ្លួនលោក **អៀង សារី** ចូលរួមក្នុងសវនាការសាជាថ្មីម្តងទៀតនោះទេ រហូតទាល់តែនៅពេលមួយដែលជនជាប់ចោទបញ្ជាក់ពីបំណងក្នុងការឆ្លើយសំណួរ ឬបញ្ចេញមតិយោបល់នៅផ្នែកណាមួយនៃដំណើរការនីតិវិធី ។ រីឯជនជាប់ចោទ **ខៀវ សំផន** វិញ បានអានសេចក្តីថ្លែងការណ៍ដែលបានរៀបចំទុកជាមុន ដែលសេចក្តីថ្លែងការណ៍នេះ គឺជាការផ្តល់មតិយោបល់ទៅលើបទចោទប្រកាន់ទាំងឡាយក្នុងដីកាដំណោះស្រាយពាក់ព័ន្ធនឹងសវនាការវគ្គទី១។ គាត់ក៏បានបញ្ជាក់ផងដែរថា គាត់នឹងមិនឆ្លើយសំណួរណាមួយឡើយរហូតទាល់តែភាគីសហព្រះរាជអាជ្ញាបានលើកបង្ហាញនូវរាល់ភស្តុតាងប្រឆាំងនឹងរូបគាត់ឲ្យចប់សព្វគ្រប់ជាមុនសិន ។

នៅមានភាពស្រពិចស្រពិលមួយចំនួន ថាតើអង្គជំនុំជម្រះត្រូវបានអនុញ្ញាតឲ្យទាញហេតុផលនៃការនៅស្ងៀមមិនឆ្លើយតបរបស់ជនជាប់ចោទដើម្បីបញ្ចូលក្នុងសេចក្តីសន្និដ្ឋានដាក់បន្ទុកដែរ ឬយ៉ាងណា ព្រោះបញ្ហានេះមិនត្រូវដោះស្រាយឡើយនៅក្នុងសំណុំរឿង០០១ នៅពេលដែលលោក **កាំង ហ្គេចអ៊ាវ** ហៅ “ឌុច” បានប្រើប្រាស់សិទ្ធិនៅស្ងៀមរបស់គាត់ ។[៣៧] ថ្វីបើច្បាប់របស់អ.វ.ត.ក និងច្បាប់កម្ពុជា ពុំមានកំណត់នូវការណែនាំណាមួយជុំវិញបញ្ហាទាំងនេះក៏ដោយ ក៏មាត្រា ៦៧ នៃ*លក្ខន្តិកៈទីក្រុងរ៉ូម* (Rome Statute) បានធានានូវសិទ្ធិរបស់ជនជាប់ចោទក្នុង “*ការរក្សាភាពស្ងៀមស្ងាត់មិនឆ្លើយតប មិនត្រូវបានចាត់ទុកថាជាការដែលអាចកំណត់ពីពិរុទ្ធភាព ឬគ្មានពិរុទ្ធភាពនោះទេ*”។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក បានធ្វើការបកស្រាយខ្លឹមសារនៃសិទ្ធិនៅស្ងៀមនេះ ដោយថាការដែលជនជាប់ចោទបានឆ្លើយតបនឹងសំណួរខ្លះៗ ឬក៏បានប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយពាក់ព័ន្ធនឹងចំណុចដទៃទៀត អាចនឹងជាលទ្ធផលក្នុងការ

ទាញហេតុផលនៃសេចក្ដីសន្និដ្ឋានដាក់បន្ទុក ដែលយើងនៅតែបានឃើញការអនុវត្តបែបនេះបន្តកើតមានក្នុងកិច្ចដំណើរការសវនាការ ។

## *ជំពូកទី៤ ៖ ការគ្រប់គ្រងសវនាការ*

នាសប្ដាហ៍នេះ ការចោទឡើងនៃបញ្ហាសុខភាព រួមជាមួយគ្នានឹងបញ្ហាបច្ចេកទេស នៅតែជាបញ្ហានាំមុខដែលនាំឲ្យមានការប៉ះពាល់ទៅលើលំហូរនៃកិច្ចដំណើរការនីតិវិធី ។ ថ្វីបើលោក **ឡុង នរិន្ទ** ត្រូវបានរំពឹងទុកថាគាត់នឹងបន្តផ្ដល់សក្ខីកម្មតាមការលៃទុកពេលវេលាជាថ្មីម្ដងទៀតរបស់អង្គជំនុំជម្រះនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ ក្រោយពីថ្ងៃឈប់សម្រាកក៏ដោយ ក៏សុខភាពរបស់គាត់នៅតែមិនស្រាកស្រាន្តសោះ នៅពេលនោះ ។ ដូច្នេះហើយ អង្គជំនុំជម្រះសាលាដំបូង បានបង្វិលការពិភាក្សាសួរដេញដោលទៅលើជនជាប់ចោទទាំងបីនាក់វិញម្ដង ។ នៅពេញមួយសប្ដាហ៍នេះ ការតាំងសំណួរដេញដោលទៅលើលោក **នួន ជា** ត្រូវបានប្រើប្រាស់ពេលវេលាកំណត់ត្រឹមតែកន្លះថ្ងៃដោយសារបញ្ហាសុខភាពរបស់គាត់ ។ ការអនុវត្តន៍បែបនេះ ទំនងជានឹងត្រូវបន្តធ្វើចំពោះជនជាប់ចោទរូបនេះនៅសវនាការជាបន្តបន្ទាប់ខាងមុខទៀត ។ អង្គជំនុំជម្រះ ក៏បានកត់សម្គាល់ផងដែរពីការលំបាករបស់លោក **នួន ជា** ក្នុងពេលគាត់ដើរទៅកាន់កន្លែងអង្គុយក្នុងរង្វង់ក្រចកសេះនៃបន្ទប់សវនាការ ហើយបានធ្វើការណែនាំឲ្យសន្តិសុខប្រើប្រាស់កៅអីរុញដើម្បីសម្រួលដល់ជនជាប់ចោទក្នុងការដើរទៅដើរមករបស់គាត់ ។

បញ្ហាផ្នែកបច្ចេកទេស ក៏បានធ្វើឲ្យប៉ះពាល់ដល់កាលវិភាគនៃកិច្ចដំណើរការនីតិវិធីរបស់សវនាការផងដែរ ។ ទោះបីជាលោក **ឡុង នរិន្ទ** មានសុខភាពធូរស្រាលល្មមអាចផ្ដល់សក្ខីកម្មនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ ក៏ដោយ ក៏អង្គជំនុំជម្រះបានធ្វើការពន្យារពេលនៃការបន្តផ្ដល់សក្ខីកម្មរបស់គាត់ ដោយបានលើកពេលវេលាទៅពេលថ្ងៃត្រង់វិញ ព្រោះតែបញ្ហារអាក់រអួលនៃឧបករណ៍សោតទស្សន៍ដែលបានកើតឡើងនៅវគ្គពេលព្រឹក ។ នៅមានបញ្ហាមួយចំនួនទៀតបានចោទឡើងផងដែរ នៅពេលលោក **ឡុង នរិន្ទ** មិនបានឆ្លើយតបឲ្យចំនឹងសំណួរ ឬមកពីមិនអាចស្ដាប់គ្នាយល់បានច្បាស់ (លទ្ធភាពនេះអាស្រ័យទៅលើប្រព័ន្ធបញ្ជូនវីដេអូរក្នុងតំបន់ដែលគាត់រស់នៅ) ។ ស្ទើរគ្រប់សំណួរដេញដោលដែលបានសួរដោយភាគី ត្រូវបានបញ្ជាក់សាឡើងវិញជូនគាត់ ។ បញ្ហាផ្នែកបច្ចេកទេសទាំងនេះ ក៏បានជួបប្រទះដូចគ្នាផងដែរនៅក្នុងបន្ទប់បកប្រែ ។ នៅពេលចាប់ផ្ដើមនៃការតាំងសំណួរដេញដោលទៅលើសាក្សីដែលរូបនេះ ដែលទំនងជាការបញ្ជូនសំឡេងបកប្រែសំណួរដេញដោលរបស់លោកចៅក្រម **ឡាវែន៍** ទៅកាន់លោក **នួន ជា** ត្រូវបានកាត់ផ្ដាច់ ។ ចំពោះអ្នកបកប្រែវិញ ត្រូវនិយាយបកប្រែឡើងវិញពីរដងមុននឹងបញ្ហាទាំងនោះត្រូវបានដោះស្រាយចប់សព្វគ្រប់។ រីឯលោក **ផេស្តមិន** ក៏បានត្អូញត្អែរដោយបានលើកនូវឧទាហរណ៍មួយ នៅពេលដែលគាត់មិនទទួលបានការបកប្រែភាសានៃសេចក្ដីថ្លែងការណ៍កំពុងជជែកពិភាក្សាក្នុងបន្ទប់តុលាការ ដែលធ្វើឡើងពីភាសាខ្មែរទៅភាសាអង់គ្លេសនោះទេ ។

### ក. ការបែងចែកពេលវេលា

អង្គជំនុំជម្រះសាលាដំបូង បានធ្វើការបែងចែកពេលវេលាដោយលៃលកពេលកន្លះថ្ងៃជារៀងរាល់ថ្ងៃក្នុងសប្ដាហ៍នេះ ដើម្បីអនុញ្ញាតឲ្យភាគីធ្វើការតាំងសំណួរដេញដោលទៅលើលោក **នួន ជា** ស្ដីពីប្រវត្តិសាស្ត្រ

នៃរបបកម្ពុជាប្រជាធិបតេយ្យ ។ មិនដូចកាលពីសប្តាហ៍មុននោះទេ អង្គជំនុំជម្រះមិនបានដាក់បញ្ញត្តិតឹងរឹងជាពិសេសណាមួយទៅលើការប្រើប្រាស់ពេលវេលារបស់លោក **ឡុង នរិន្ទ**ឡើយ ពោលគឺអង្គជំនុំជម្រះបានអនុញ្ញាតឲ្យភាគីទាំងអស់សួរសំណួរដេញដោលទៅកាន់សាក្សីរូបនេះ នៅគ្រប់ទិដ្ឋភាពទាំងអស់នៅក្នុងសំណុំរឿង០០២ ។ នៅពេលដែលមេធាវីអន្តរជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីលោកស្រី **អេលីហ្សាបេត ស៊ីម៉ុនណូហ្វត** បានសួរពីមូលហេតុនៃការបែងចែកពេលវេលាសម្រាប់ក្រុមមេធាវីការពារក្តីក្នុងការសួរដេញដោលទៅលើលោក **ឡុង នរិន្ទ** អង្គជំនុំជម្រះបានពន្យល់ថា អង្គជំនុំជម្រះមិនបានធ្វើការបែងចែកពេលវេលាឲ្យជាក់លាក់ណាមួយក្នុងការតាំងសំណួរដេញដោលទៅលើជនជាប់ចោទ និងសាក្សីឡើយ និងថា ការធ្វើបែបនេះ គឺក្នុងគោលបំណងសម្របសម្រួលដល់ការលំបាកទាក់ទងនឹងកម្រិតនៃការយល់ដឹងផ្សេងគ្នា ដែលប្រការទាំងនេះអាចជាការរំខានក្នុងកិច្ចដំណើរការនីតិវិធី បញ្ហាបច្ចេកទេស និង បញ្ហាដែលត្រូវគិតគូរផងដែរនោះ គឺភាពចាស់ជរា និងសុខភាពរបស់ពួកគាត់ ។

## ខ. បញ្ហានៃការបកប្រែភាសា

នាសប្តាហ៍នេះ មានភាពមិនត្រឹមត្រូវខ្លះៗបានកើតមានឡើងនៅក្នុងពេលធ្វើការបកប្រែភាសាឃ្លាប្រយោគមួយចំនួន។ ជាឧទាហរណ៍ មានការបកប្រែខុសនូវកាលបរិច្ឆេទនៃព្រឹត្តិការណ៍មួយ ដែលជាភាសាអង់គ្លេសឮថា ឆ្នាំ "១៩៧៥" ជាជាងឆ្នាំ "១៩៥៥"។ ប្រការនេះ ជាក្តីបារម្ភមួយដ៏សំខាន់ ពីព្រោះចម្លើយរបស់សាក្សីតបនឹងសំណួរគឺពឹងផ្អែកជាចំបងទៅលើកាលបរិច្ឆេទដែលភាគីម្ចាស់សំណួរផ្តល់ឲ្យពួកគាត់ ។ ការពន្យារពេលក្នុងការបកប្រែបានរារាំងមិនឲ្យភាគីធ្វើការជំទាស់ភ្លាមៗ ឬទាន់សភាពការណ៍ ។ មានករណីមួយនោះ អង្គជំនុំជម្រះបានដាស់តឿនលោក **លីសាក់** ឲ្យធ្វើការលើកឡើងនូវការជំទាស់របស់ខ្លួនទៅនឹងសំណួររបស់លោក **សុន អារុណ** ឲ្យបានទាន់ពេល ពោលគឺភ្លាមៗក្រោយស្តាប់សំណួរចប់។ លោក **លីសាក់** បានតវ៉ា និង បានលើកហេតុផលពីការពន្យារនៃការបកប្រែភាសាក្នុងពេលគាត់បានស្តាប់ឮនូវសំណួរណាមួយដែលអាចធ្វើការជំទាស់បាន តែសាក្សីបានឆ្លើយតបរួចជាស្រេចទៅហើយ ។ និយាយជារួម បញ្ហានៃការបកប្រែភាសាដែលបានកើតមានឡើងកន្លងមក អាចនឹងធ្វើឲ្យមានផលប៉ះដល់លំហូរ និងគុណភាពនៃកិច្ចដំណើរការនីតិវិធីសវនាការមួយនេះ ។

## គ. បរិយាកាសរបស់ចៅក្រម និងមេធាវី

បរិយាកាសនៅក្នុងបន្ទប់សវនាការ បានក្លាយជាបញ្ហាមួយដែលត្រូវបានលើកឡើងនាសប្តាហ៍នេះ នៅពេលដែលមេធាវី **វែកគែន** បានជំឡើងសរសៃកដាក់គ្នាទៅវិញទៅមកជាមួយនឹងអង្គចៅក្រមជំនុំជម្រះ។ ពេលនោះ មេធាវីបានព្យាយាមជជីករកឬសគល់ឲ្យមានការឆ្លើយបំភ្លឺពីអង្គជំនុំជម្រះទៅលើការទទូចទាមទាររបស់គាត់កាលពីមុនស្តីពីភាពអាចទទួលយកបាននៃឯកសារ និងបញ្ហានៃការបកប្រែឯកសារជាភាសាផ្លូវការរបស់តុលាការ បើទោះបីជាមានការបកស្រាយពីរបីលើកដោយអង្គជំនុំជម្រះហើយក៏ដោយ ។ ប្រធានអង្គជំនុំជម្រះវិញ ក៏បានជំឡើងសំឡេងតបនៅពេលដែលគាត់ផ្តល់ការទូន្មានដល់លោក **វែកគែន** និងបានប្រកាសថាមេធាវីនឹងមិនត្រូវបានផ្តល់វេទិកាឲ្យឡើយ បើនៅតែលើកយកបញ្ហានេះមកជជែកទៀត ។ នៅពេលនោះលោក **វែកគែន** បានព្យាយាមធ្វើការឆ្លើយតប ក៏ប៉ុន្តែប្រធានប្រធានបានកាត់ផ្តាច់ម៉ៃក្រូហ្វូនរបស់មេធាវីការពារក្តីរូបនេះ ។ សេចក្តីរម្លឹកមួយ ត្រូវបានធ្វើឡើងផងដែរដល់ភាគីទាំងអស់ ដោយត្រូវតែស្នើសុំការអនុញ្ញាតពីអង្គ

ជំនុំជម្រះជាមុនសិនមុនពេលចង់ក្រោកឈរថ្លែងនូវសេចក្តីថ្លែងការណ៍អ្វីមួយ ។ នៅចុងបញ្ចប់នៃវគ្គពិភាក្សាចុងក្រោយនេះ មេធាវីអន្តរជាតិការពារក្តីលោក **នួន ជា** គឺលោក **អេនទ្រូ អ៊ីនូហ្សី** បានថ្លែងអំណរគុណទៅកាន់សហការីរបស់គាត់ដែលធ្វើការក្នុងក្រុមការពារក្តី និង បានអញ្ជើញពួកគេឲ្យចូលរួមទទួលទានភេជ្ជសៈជាមួយគ្នាបន្ទាប់ពីចប់សវនាការជាសាធារណៈ (សប្តាហ៍នេះ) ។ ការលើកឡើងមិនសមរម្យខាងលើនេះបានធ្វើឲ្យមានការគ្រេនរំឭកភ្លាមៗពីសំណាក់ចៅក្រម **ខាតរ៉ាយច៍** ។ លោកស្រីបានថ្លែងថា នេះគឺជាការគ្រេនរំឭកមួយដល់ភាគីទាំងអស់ ត្រូវតែប្រើប្រាស់ពេលវេលារបស់ផងខ្លួននៅក្នុងការបំពេញតួនាទីឲ្យមានប្រសិទ្ធភាព និងដោយការយកចិត្តទុកដាក់ ហើយក៏ត្រូវតែកំណត់នូវការពិភាក្សាដែលខ្លួនចង់លើកឡើងឲ្យបានច្បាស់លាស់ ដោយលើកត្រឹមតែបញ្ហាដែលមានភាពពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនីតិវិធីតែប៉ុណ្ណោះ ។

ស្របពេលជាមួយគ្នានេះផងដែរ អង្គជំនុំជម្រះគួរតែអនុវត្តនូវការឆ្លើយតបឲ្យបានម៉ឺងម៉ាត់ជាអតិបរមាក្នុងពេលដែលត្រូវផ្តល់ការទូន្មានដល់ភាគី ជាពិសេសនៅពេលមានបញ្ហាគតិយុត្តិសំខាន់ៗ ក៏ដូចជាបញ្ហានីតិវិធីនានាដែលអាចនឹងកើតឡើងនៅពេលក្រោយៗទៀត ។

## ឃ. តារាងពេលវេលា

| កាលបរិច្ឆេទ | ចាប់ផ្តើម | សម្រាកពេលព្រឹក | អាហារថ្ងៃត្រង់ | សម្រាកពេលរសៀល | ផ្អាកសវនាការ | រយៈពេលសវនាការសរុប |
|---|---|---|---|---|---|---|
| ថ្ងៃអង្គារ ១៣/១២/១១ | ៩:០១ | ១០:៤៤-១១:០៧ | ១២:០៥-១៣:៣៣ | ១៤:៥០-១៥:១៩ | ១៦:១០ | ៤ម៉ោង និង ៤៩នាទី |
| ថ្ងៃពុធ ១៤/១២/១១ | ៩:០២ | ១០:០៨-១០:៣៣ | ១២:០៦-១៣:៣២ | ១៤:៣៥-១៤:៥៥ | ១៦:០៤ | ៤ម៉ោង និង ៥១នាទី |
| ថ្ងៃព្រហស្បតិ៍ ១៥/១២/១១ | ៩:០១ | ១០:១៨-១០:៤២ | ១២:០៣-១៣:៣១ | ១៤:៤៣-១៥:១១ | ១៥:៥៤ | ៤ម៉ោង និង ៣៣នាទី |
| ០៨/១១/១២ | ៩:១០ | ១០:៣២-១០:៥០ | ១២:០៧-១៣:៣២ | ១៤:២០-១៤:៤០ | ១៦:០៥ | ៤ម៉និង៥២នាទី |

| | |
|---|---|
| *រយៈពេលសវនាការជាមធ្យម* | *៤ម៉ោង និង៤៤នាទី* |
| *រយៈពេលសវនាការសរុបក្នុងសប្តាហ៍នេះ* | *១៩ម៉ោង និង១៣នាទី* |
| *ចំនួនម៉ោង ថ្ងៃ និងសប្តាហ៍នៃសវនាការ* | *៤៤ម៉ោង និង៧នាទី* |
| ***រយៈពេលសវនាការចំនួន ១០ថ្ងៃ អំឡុងពេល ៣សប្តាហ៍*** | |

**Unless specified otherwise,**

- the documents cited in this report pertain to *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* before the ECCC;
- the quotes are based on the personal notes of the trial monitors during the proceedings;
- the figures in the *Public Attendance* section of the report are only approximations; and
- photos are courtesy of the ECCC.

**Glossary of Terms**

| | |
|---|---|
| Case 001 | *The Case of Kaing Guek Eav alias "Duch"*(Case No. 001/18-07-2007-ECCC) |
| Case 002 | *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* (Case No. 002/19-09-2007-ECCC) |
| CPC | Code of Criminal Procedure of the Kingdom of Cambodia (2007) |
| CPK | Communist Party of Kampuchea |
| CPLCL | Civil Party Lead Co-Lawyer |
| DK | Democratic Kampuchea |
| ECCC | Extraordinary Chambers in the Courts of Cambodia (also referred to as the Khmer Rouge Tribunal or "KRT") |
| ECCC Law | Law on the Establishment of the ECCC, as amended (2004) |
| ERN | Evidence Reference Number (the page number of each piece of documentary evidence in the Case File) |
| FUNK | National United Front of Kampuchea |
| GRUNK | Royal Government of National Union of Kampuchea |
| ICC | International Criminal Court |
| ICCPR | International Covenant on Civil and Political Rights |
| ICTR | International Criminal Tribunal for Rwanda |
| ICTY | International Criminal Tribunal for the former Yugoslavia |
| IR | Internal Rules of the ECCC Rev. 8 (2011) |
| KR | Khmer Rouge |
| OCIJ | Office of the Co-Investigating Judges |
| OCP | Office of the Co-Prosecutors of the ECCC |
| RAK | Revolutionary Army of Kampuchea |
| VSS | Victims Support Section |
| WESU | Witness and Expert Support Unit |

EAST-WEST CENTER

AIJI TRIAL MONITORING

WAR CRIMES STUDIES CENTER UNIVERSITY OF CALIFORNIA, BERKELEY

---

*

*AIJI is a collaborative project between the East-West Center, in Honolulu, and the War Crimes Studies Center, University of California, Berkeley. Since 2003, the two Centers have been collaborating on projects relating to the establishment of justice initiatives and capacity-building programs in the human rights sector in South-East Asia. The Program is funded by the Open Society Foundation, the Foreign Commonwealth Office of the British Embassy in Phnom Penh, and the Embassy of Switzerland in Bangkok.

This issue of **KRT TRIAL MONITOR** was authored by Samantha Lee, Danel Mattes, Aviva Nababan,SovannaSek, Kimsan Soy,and Penelope Van Tuyl, as part of AIJI's KRT Trial Monitoring and

Community Outreach Program. KRT TRIAL MONITOR reports on Case 002 are available at <www.krtmonitor.org>, and at the websites of the East-West Center and the War Crimes Studies Center.

១ Office of the Co-Investigating Judges. "Closing Order" (15 September 2010). D427 [hereinafter, CLOSING ORDER]. Par.19.13. "...the Indochinese Communist Party (ICP)... was officially dissolved in 1951 and its former members were supposed to establish separate revolutionary organizations for each country. The new partycreated in Cambodia was the Khmer People's Revolutionary Party ("KPRP")..." The KPRP was renamed"Workers Party of Kampuchea." See CLOSING ORDER. par.20.13, which states, "Official CPK documents andstatements, post-17 April 1975, identify the 1960 Congress, at which the KPRP became a "Workers Party", as thereal starting point of the Cambodian communist movement." Later, the Workers Party was referred to as the Communist Party of Kampuchea. See, CLOSING ORDER. par.23.14. "In a Central Committee meeting held in September or October 1966, the leaders decided to change the name of the Party to CPK (although that decisionwas kept secret until the next Party Congress)..." See also, Library of Congress, Appendix-B – Cambodia: Major Political and Military Organizations, "KCP," "KPRP". Available at <http://lcweb2.loc.gov/frd/cs/cambodia/kh_appnb.html>, accessed on 9 February, 2012.

២ Trial Chamber. Transcript of Hearing (15 December 2011). E1/23.1.(hereinafter,"15 DECEMBER TRANSCRIPT). 32. Line 16.

៣ Ibid., at lines 16-19.

៤ Ibid., at 34, lines 24-25.

៥ Ibid.

៦ Trial Chamber. Transcript ofHearing (13 December 2011). E1/23.1. (hereinafter, "13 DECEMBER TRANSCRIPT). 5. Lines 23-25; 6. 1.

៧ Ibid., at 9. Line 14.

៨ Ibid., at 11. Lines 8-9.

៩ Ibid., at Lines 23-5; 12. Line 1.

១០ Trial Chamber. Transcript of Hearing (14 December 2011).E1/23.1. (hereinafter, "14 DECEMBER TRANSCRIPT).
5. Lines 19-21.

១១ Ibid., at 23. Lines 15-16.

១២ 13 DECEMBER TRANSCRIPT. 39. Lines 22-25; 40. 1-3.

១៣ Ibid., at 42. Lines 12-3.

១៤ Ibid., at Lines 17-24.

១៥ 15 DECEMBER TRANSCRIPT. 88. Line 25. 89. Line 1.

១៦ 13 DECEMBER TRANSCRIPT. 32. Lines 4-5.

១៧ Ibid., at lines 7-9.

១៨ Ibid., at 51. Lines 21-22.

១៩ Ibid., at 52. Line 7.

២០ 14 DECEMBER TRANSCRIPT. 6. Lines 21-25. 7. Lines 1-6.

២១ 13 DECEMBER TRANSCRIPT. 94. Lines 7-13.

២២ See CLOSING ORDER. 15. par. 25.

២៣ 13 December Transcript. 94. Lines 21-24.

២៤ Ibid., at lines 15-16.

២៥ 14 December Transcript. 77. Lines 3-4.

២៦ The Ministry of Foreign Affairs was also referred to as “B-1” during the regime.

២៧ The author Mr. Thet Sambath confirmed this in a newspaper article; see The Phnom Penh Post, “Film’s Use at Trial Questioned,” 15 December 2011.

២៨ Rule 83(3) in Version 3 did not provide for appropriate identification in court as a means of putting documents before the Chamber. It reads: “... Evidence from the case file is considered put before the Chamber if its content has been summarised or read out in court.”

២៩ AIJI. KRT Trial Monitor, Case 001.“Lessons Learned from the ‘Duch’ Trial.” (December 2009). 23. See also, KRT Trial Monitor, Case 001, Report Nos. 6 (week ending 24 May 2009); 9 (week ending 21 June 2009); 16. (week ending 10 August 2009)and 21 (week ending 20 September 2009).

៣០ Rule 87(3) has not been amended since Version 4 of the Internal Rules.

៣១ See Trial Chamber. “Witness Lists for Early Trial Segments, Deadline for Filing of Admissibility Challenges toDocuments and Exhibits, and Response to Motion E109/5” (25 October 2011).E131/1. par.4. 3.

៣២ Ibid.

៣៣ Internal Rules. Rule 25.2; Rule 55.7.

៣៤ 15 December Transcript. 15. Line 18.

៣៥ Presently, His Excellency Keat Chhon is Cambodia’s Minister of Finance and Economy.

៣៦ Ibid., at 101. Lines 10-12.

៣៧ In Case 001, while the Accused Duch answered majority of the questions, he chose not to answer certain questions (e.g. on 29 April 2009), exercising his right to remain silent. In its Judgment issued on 26 July 2010 the Trial Chamber did not state whether or not it had drawn adverse inferences from these choices.